# សាវ័កនាសម័យចុងក្រោយ

SEVENTH-DAY ADVENTIST CHURCH

# ព្រះយេស៊ូវនឹងយាងមកឆាប់ៗ!

## ពួកសាវ័កនាសម័យចុងក្រោយ មេរៀន ទី១



## សរសើរតម្កើងព្រះ និងអធិស្ឋាន

- តើលោកអ្នកអាចសរសើរតម្កើងព្រះ សំរាប់រឿងរ៉ាវថ្មីៗកន្លងមកនេះខ្លះទេ?
- ថ្មីៗនេះ តើមានអ្វីខ្លះ ដែលលោកអ្នកកំពុងព្រួយបារម្ភ ឬទេ?

## ការសិក្សាព្រះបន្ទូលរបស់ព្រះ

១) ចូរអាន ម៉ាថាយ ២៤:២៣-៣១។ តើមានហេតុការណ៍អ្វីខ្លះដែលបង្ហាញថា ព្រះយេស៊ូវនឹងយាងមកកាន់ផែនដីវិញឆាប់ៗ?

២) ឧបមាថា មាននរណាម្នាក់បានមកអះអាងថា ខ្លួនគេជាព្រះយេស៊ូវ ព្រមទាំងបានព្យាបាលមនុស្សរាប់ពាន់នាក់ឲ្យបានជា ពីជំងឺផ្សេងៗផង។ តើលោកអ្នកដឹងដោយរបៀបណាថា គាត់នោះគឺជាព្រះយេស៊ូវក្លែងក្លាយ?

៣) ចូរអាន ថែស្សាឡូនីចទី១ ៤:១៥-១៨។ ពេលព្រះយេស៊ូវយាងមកវិញ តើមានអ្វីកើតឡើងដល់អស់អ្នក ដែលបានស្លាប់ទៅហើយ ដោយបានជឿលើព្រះយេស៊ូវ និងអស់អ្នកកំពុងរស់នៅ និងកំពុងជឿលើព្រះគ្រិស្ត?

៤) ចូរអាន យ៉ូហាន ១៤:១-៣។ តើព្រះយេស៊ូវបានសន្យាអ្វីខ្លះមុនពេលដែលព្រះអង្គយាងទៅនគរឋានសួគ៌?

៥) ចូរអាន យ៉ូហាន ១៤:៤-៦។ តើយើងអាចទៅនគរឋានសួគ៌បានដោយរបៀបណា?

៦) ចូរអាន ពេត្រុសទី២ ៣:៩។ ហេតុអ្វីបានជាព្រះយេស៊ូវមិនទាន់យាងមកនៅឡើយ?

៧) ចូរអាន ពេត្រុសទី២ ៣:១០។ តើមានអ្វីនឹងកើតឡើងចំពោះផែនដីរបស់យើងនិងមនុស្សទុច្ចរិត ពេលព្រះយេស៊ូវយាងមកវិញ?

៨) ចូរអាន ពេត្រុសទី២ ៣:១១-១៤។ ដោយដឹងថាព្រះយេស៊ូវនឹងយាងមកឆាប់ៗនេះ តើយើងគួរធ្វើអ្វីខ្លះ?

៩) តើលោកអ្នកមានអារម្មណ៍រំភើបញាប់ញ័រយ៉ាងណាអំពីការយាងមកវិញរបស់ ព្រះយេស៊ូវឆាប់ៗនេះ?

១០) ចូរអាន ថែស្សាឡូនីចទី១ ៥:៨-១១។ តើខសន្យានេះជួយលើកទឹកចិត្តលោកអ្នកយ៉ាងណាដែរ?

១១) ចូរចំណាយពេលស្ងប់ស្ងាត់មួយរយៈពេល ដើម្បីគិតអំពីអ្វីដែលលោកអ្នកបានរៀនអំបាញ់មិញនេះ។ ចូរសូមឲ្យព្រះជាម្ចាស់បង្ហាញដល់លោកអ្នកបន្ថែមទៀតប្រសិនបើមានអ្វីដែលត្រូវផ្លាស់ប្តូរនៅក្នុងចិត្ត និង ជីវិតរបស់លោកអ្នកដើម្បីត្រៀមខ្លួនជាស្រេចទទួលការយាងមកវិញរបស់ព្រះយេស៊ូវ?

## ចែកចាយ និងអធិស្ឋាន

□ នៅថ្ងៃនេះ តើលោកអ្នកបានរៀនអ្វីខ្លះដែលលោកអ្នកអាចនឹងយកទៅអនុវត្តនៅសប្តាហ៍នេះ ដោយពឹងលើអំណាចរបស់ព្រះជាម្ចាស់?

□ ចូរពិភាក្សាអំពីសេចក្តីត្រូវការក្នុងគ្រួសារ និងសហគមន៍ព្រមទាំងការប្តេជ្ញាចិត្តរបស់លោកអ្នក ហើយសំរេចចិត្តថា តើមានអ្វីខ្លះដែលលោកអ្នកអាចជួយបាន?

□ សូមអធិស្ឋានឲ្យគ្នាទៅវិញទៅមក សំរាប់គ្រួសារនិងសហគមន៍របស់លោកអ្នកនៅពេលនេះចុះ។

## កិច្ចការពិសេស ឬកិច្ចអនុវត្តន៍

□ ចូរទន្ទេញ ថែស្សាឡូនីចទី១ ៥:៩

□ ចូរចែកចាយប្រាប់ទៅអ្នកដទៃឲ្យបានយ៉ាងតិចណាស់ម្នាក់អំពីការយាងមកវិញឆាប់ៗរបស់ព្រះយេស៊ូវ និងរបៀបត្រៀមខ្លួនទទួលព្រះអង្គ។

(ខព្រះគម្ពីរផ្សេងទៀតស្តីពីការយាងមកវិញរបស់ព្រះយេស៊ូវៈ វិវរណៈ១:៧; កូរិនថូសទី១ ១៥:៥០-៥៨ យ៉ូប ១៩:២៥-២៧)។

# ចុងបញ្ចប់នៃអំពើបាប

## ពួកសាវ័កនាសម័យចុងក្រោយ មេរៀន ទី២



## សរសើរតម្កើងព្រះ និងអធិស្ឋាន

- តើលោកអ្នកមានអ្វីសរសើរតម្កើងព្រះទេ បន្ទាប់ពីយើងជួបគ្នាកន្លងមកនេះ?
- ថ្មីៗនេះតើមានអ្វីខ្លះដែលលោកអ្នកកំពុងព្រួយបារម្ភដែរទេ?
- សូមអធិស្ឋានសំរាប់សេចក្តីត្រូវការឲ្យគ្នាទៅវិញទៅមក។ ចូរសូមព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណបរិសុទ្ធស្ថិតក្នុងការជួបប្រជុំគ្នានេះ។

## ការរំឭកឡើងវិញ

- ចូរសូត្រខចងចាំជាមួយដៃគូម្នាក់ ឬពីរនាក់។
- តើលោកអ្នកបានរៀនអ្វីខ្លះកាលពីលើកមុន?
- តើមានការប្រែប្រួលអ្វីខ្លះក្នុងជីវិតរបស់អ្នក ដោយព្រោះសេចក្តីពិតដែលអ្នកបានរៀនពីមេរៀនមុននោះ?
- តើលោកអ្នកបានចែករំលែកអ្វីដែលបានរៀនកន្លងមកទៅកាន់នរណាខ្លះ?

## ការសិក្សាព្រះបន្ទូលរបស់ព្រះ

១) ចូរអាន យេរេមា ២៥:៣១-៣៣។ តើមានអ្វីកើតឡើងចំពោះមនុស្សទុច្ចរិតនៅពេលព្រះយេស៊ូវយាងមកវិញ?

២) ចូរអាន យេរេមា ៤:២៣-២៦។ តើមានអ្វីកើតឡើងចំពោះផែនដីនៅពេលព្រះយេស៊ូវត្រឡប់មកវិញ?

៣) ចូរអាន វិវរណៈ ២០:១-៣ តើមានអ្វីកើតឡើងចំពោះសាតាំងនិងទេវតាអាក្រក់របស់វានៅពេលព្រះយេស៊ូវយាងមកវិញ?

៤) ចូរអាន ថែស្សាឡូនីចទី១ ៤:១៦-១៨។ តើមានអ្វីកើតឡើងចំពោះមនុស្សសុចរិតនៅពេលព្រះយេស៊ូវយាងត្រឡប់មកវិញ?

៥) ចូរអាន វិវរណៈ ២០:៤-៦ និងកូរិនថូសទី១ ៦:២-៣។ តើមនុស្សសុចរិតនឹងធ្វើអ្វីនៅនគរឋានសួគ៌ក្នុងកំឡុងពេល១០០០ឆ្នាំ?

៦) នៅនគរឋានសួគ៌ព្រះវិស្តររបស់ព្រះនឹងជំនុំជំរះមនុស្សទុច្ចរិតនិងទេវតាអាក្រក់។ រឿងនេះមានន័យថា ពួកគេនឹងពិនិត្យមើលបញ្ជីកំណត់ហេតុ និងមើលភស្តុតាងដែលព្រះទ្រង់បានព្យាយាមជួយសង្គ្រោះបាបជន

និងប្រតិកម្មដែលពួកគេច្រានចោលសេចក្ដីមេត្តាករុណារបស់ព្រះអង្គ។ បន្ទាប់មកទើបពួកគេយល់ច្បាស់ថា ហេតុអ្វីបានជាមិត្តភក្តិនិងសាច់ញាតិខ្លះរបស់ពួកគេមិនមានវត្តមាននៅជាមួយពួកគេនៅនគរឋានសួគ៌។ សូមអាន វិវរណៈ ៧:១៥-១៧។ តើព្រះទ្រង់នឹងធ្វើអ្វីចំពោះអស់អ្នកដែលនៅនគរឋានសួគ៌ខណៈដែលពួកគេយំអាឡោះអាល័យសាច់ញាតិនិងមិត្តភក្តិដែលច្រានចោលសេចក្ដីសង្គ្រោះរបស់ព្រះជាម្ចាស់?

៧) បន្ទាប់ពី១000ឆ្នាំ ព្រះទ្រង់នឹងលើកយកក្រុងយេរូសាឡិមពីនគរឋានសួគ៌មកដាក់លើផែនដី។ នោះនឹងមានការរស់ឡើងវិញជាលើកទីពីរនៅផែនដីគឺព្រះទ្រង់នឹងប្រោសមនុស្សទុច្ចរិតដែលស្លាប់ឲ្យរស់ឡើងវិញ។ សូមអាន វិវរណៈ ២០:៧-១០។ តើមានអ្វីកើតឡើងចំពោះសាតាំងនិងមនុស្សទុច្ចរិត?

៨) ចូរអាន ម៉ាឡាគី ៤:១ និងអេសេគាល ២៨:១៨-១៩។ តើសាតាំងនិងមនុស្សទុច្ចរិតនឹងចេះតែបន្តឆេះជារៀងរហូត ឬគ្រាន់តែឆេះអស់ចប់?

៩) ចូរអាន វិវរណៈ ២០:១១-១២។ មុនពេលដែលព្រះទ្រង់បំផ្លាញមនុស្សទុច្ចរិត តើព្រះទ្រង់នឹងអនុញ្ញាតឲ្យពួកគេឃើញនិងយល់ដឹងអ្វីខ្លះ?

១0) ចូរអាន វិវរណៈ ២១:១-៧។ នៅពេលដែលព្រះទ្រង់បង្កើតផែនដីឡើងវិញ តើផែនដីនោះនឹងដូចជាអ្វី?

១១) ចូរអាន ទីតុស ២:១១-១៤។ តើព្រះយេស៊ូវចង់ធ្វើអ្វីក្នុងជីវិតរបស់យើងរាល់គ្នាដើម្បីត្រៀមខ្លួនសំរាប់ការយាងមកវិញឆាប់ៗរបស់ព្រះអង្គ។

១២) ចូរចំណាយពេលស្ងប់ស្ងាត់មួយរយៈពេល ដើម្បីគិតអំពីអ្វីដែលលោកអ្នកបានរៀនអំបាញ់មិញនេះ។ ចូរសូមឲ្យព្រះជាម្ចាស់បង្ហាញដល់លោកអ្នកបន្ថែមទៀតប្រសិនបើមានអ្វីដែលត្រូវផ្លាស់ប្ដូរនៅក្នុងចិត្ត និងជីវិតរបស់លោកអ្នកដើម្បីត្រៀមខ្លួនជាស្រេចទទួលការយាងមកវិញរបស់ព្រះយេស៊ូវ?

## ចែកចាយ និងអធិស្ឋាន

- ☐ នៅថ្ងៃនេះ តើលោកអ្នកបានរៀនអ្វីខ្លះដែលលោកអ្នកអាចនឹងយកទៅអនុវត្តនៅសប្ដាហ៍នេះ ដោយពឹងលើអំណាចរបស់ព្រះជាម្ចាស់?
- ☐ ចូរពិភាក្សាអំពីសេចក្ដីត្រូវការក្នុងគ្រួសារ និងសហគមន៍ព្រមទាំងការប្ដេជ្ញាចិត្តរបស់លោកអ្នក ហើយសំរេចចិត្តថា តើមានអ្វីខ្លះដែលលោកអ្នកអាចជួយបាន?
- ☐ សូមអធិស្ឋានឲ្យគ្នាទៅវិញទៅមក សំរាប់គ្រួសារនិងសហគមន៍របស់លោកអ្នកនៅពេលនេះចុះ។

## កិច្ចការពិសេស ឬកិច្ចអនុវត្តន៍

- ☐ **ចូរទន្ទេញ វិវរណៈ ២១:៤**
- ☐ ចូរចែកចាយប្រាប់ទៅអ្នកដទៃឲ្យបានយ៉ាងតិចណាស់ម្នាក់អំពីការយាងមកវិញឆាប់ៗរបស់ព្រះយេស៊ូវ និង របៀបត្រៀមខ្លួនទទួលព្រះអង្គ។
(ខព្រះគម្ពីរផ្សេងទៀតស្ដីពីការយាងមកវិញរបស់ព្រះយេស៊ូវ៖ អេសាយ ៣៥:១-១១; អេសាយ ១១:៦-៩; វិវរណៈ ២១:១០-១៧; ២២:១-៥)។

# សំលៀកបំពាក់អាពាហ៍ពិពាហ៍

## ពួកសាវ័កនាសម័យចុងក្រោយ មេរៀន ទី៣



### សរសើរតម្កើងព្រះ និងអធិស្ឋាន

- តើលោកអ្នកមានអ្វីសរសើរតម្កើងព្រះទេ បន្ទាប់ពីយើងជួបគ្នាកន្លងមកនេះ?
- ថ្មីៗនេះតើមានអ្វីខ្លះដែលលោកអ្នកកំពុងព្រួយបារម្ភដែរទេ?
- សូមអធិស្ឋានសំរាប់សេចក្តីត្រូវការឲ្យគ្នាទៅវិញទៅមក។ ចូរសូមព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណបរិសុទ្ធស្ថិតក្នុងការជួបប្រជុំគ្នានេះ។

### ការរំឭកឡើងវិញ

- ចូរសូត្រខចងចាំជាមួយដៃគូម្នាក់ ឬពីរនាក់។
- តើលោកអ្នកបានរៀនអ្វីខ្លះកាលពីលើកមុន?
- តើមានការប្រែប្រួលអ្វីខ្លះក្នុងជីវិតរបស់អ្នក ដោយព្រោះសេចក្តីពិតដែលអ្នកបានរៀនពីមេរៀនមុននោះ?
- តើលោកអ្នកបានចែករំលែកអ្វីដែលបានរៀនកន្លងមកទៅកាន់នរណាខ្លះ?

### ការសិក្សាព្រះបន្ទូលរបស់ព្រះ

១) ចូរអាន ម៉ាថាយ ២២:១-១៤។ តើលោកអ្នកគិតថាស្តេចនិងរាជបុត្ររបស់ព្រះអង្គតំណាងឲ្យអ្វីក្នុងរឿងប្រៀបធៀបនេះ?

២) ក្នុងរឿងប្រៀបធៀបនេះ មានតួអង្គដែលបានច្រានចោលការអញ្ជើញរបស់ស្តេចឲ្យចូលរួមក្នុងវិវាហមង្គលការហើយថែមទាំងបានវាយធ្វើបាបព្រមទាំងសំឡាប់ពួករាជបំរើដែលជាអ្នកទៅអញ្ជើញពួកគេ។ តើពួកគេទាំងនោះតំណាងឲ្យអ្នកណា?

៣) បន្ទាប់ពីមិត្តភក្តិបដិសេធមិនមកចូលរួម តើបានអញ្ជើញអ្នកណាឲ្យមកចូលរួមវិញ?

៤) នៅជំនាន់រឿងនិទាននេះ កាលណាស្តេចអញ្ជើញភ្ញៀវឲ្យចូលរួមពិធីវិវាហមង្គលការ ព្រះអង្គបានប្រទាននូវសំលៀកបំពាក់ពិសេសមកជាមួយដែរ។ សូមអាន វិវរណៈ ១៩:៧-៩។ តើសំលៀកបំពាក់អាពាហ៍ពិពាហ៍នេះតំណាងឲ្យអ្វី?

៥) ចូរអាន អេសាយ ៦៤:៤-៦។ តើអំពើល្អរបស់យើងរាល់គ្នាប្រៀបដូចជាអ្វី?

៦) សូមអាន អេសាយ ៦១:១០។ ដោយហេតុតែសំលៀកបំពាក់អាពាហ៍ពិពាហ៍តំណាងឲ្យសេចក្តីសុចរិត ហើយយើងរាល់គ្នាមិនមានវាដោយផ្ទាល់ខ្លួនទេ តើសេចក្តីសុចរិតនោះជារបស់អ្នកណាទៅវិញ?

៧) សូមអាន កូឡុស ៣:៨-១៤។ សូមពិពណ៌នាអំពីប្រភេទសំលៀកបំពាក់ដែលយើងត្រូវដោះចេញ និង ប្រភេទដែលត្រូវបំពាក់វិញ?

៨) ក្នុងរឿងប្រៀបធៀប បុរសដែលបានព្យាយាមចូលរួមពិធីរៀបអាពាហ៍ពិពាហ៍ដោយពុំទទួលអំណោយ ដែលជាសំលៀកបំពាក់របស់ស្តេច ត្រូវបានបោះចេញទៅក្រៅ។ ចូរអាន វិវរណៈ ១៦:១៥។ តើលោកអ្នកគិតថា នឹងមានអ្វីកើតឡើងចំពោះពួកអ្នកដែលចង់បានការអត់ទោសរបស់ព្រះប៉ុន្តែ បដិសេធមិនព្រមឲ្យព្រះអង្គផ្លាស់ប្តូរអត្តចរិតរបស់ខ្លួននោះ?

៩) ចូរអាន វិវរណៈ ៧:១៤។ បន្ទាប់ពីយើងក្លាយជាអ្នកជឿព្រះយេស៊ូវ និងទទួលសេចក្តីសង្គ្រោះ ហើយ ជាញយៗ យើងនៅតែដួលចុះ និងប្រឡូកប្រឡាក់នឹងអំពើបាបទៀត។ តើយើងអាចលាងសំអាត សំលៀកបំពាក់ដែលយើងពាក់ដោយរបៀបណា?

១០) ចូរចំណាយពេលស្ងប់ស្ងាត់មួយរយៈពេល ដើម្បីគិតអំពីអ្វីដែលលោកអ្នកបានរៀនអំបាញ់មិញនេះ។ ចូរសូមឲ្យព្រះជាម្ចាស់បង្ហាញដល់លោកអ្នកបន្ថែមទៀតប្រសិនបើមានអ្វីដែលត្រូវផ្លាស់ប្តូរនៅក្នុងចិត្ត និង ជីវិតរបស់លោកអ្នកដើម្បីត្រៀមខ្លួនជាស្រេចទទួលការយាងមកវិញរបស់ព្រះយេស៊ូវ?

## ចែកចាយ និងអធិស្ឋាន

- □ នៅថ្ងៃនេះ តើលោកអ្នកបានរៀនអ្វីខ្លះដែលលោកអ្នកអាចនឹងយកទៅអនុវត្តនៅសប្តាហ៍នេះ ដោយពឹងលើអំណាចរបស់ព្រះជាម្ចាស់?
- □ ចូរពិភាក្សាអំពីសេចក្តីត្រូវការក្នុងគ្រួសារ និងសហគមន៍ព្រមទាំងការប្តេជ្ញាចិត្តរបស់លោកអ្នក ហើយសំរេចចិត្តថា តើមានអ្វីខ្លះដែលលោកអ្នកអាចជួយបាន?
- □ សូមអធិស្ឋានឲ្យគ្នាទៅវិញទៅមក សំរាប់គ្រួសារនិងសហគមន៍របស់លោកអ្នកនៅពេលនេះចុះ។

## កិច្ចការពិសេស ឬកិច្ចអនុវត្តន៍

- □ ចូរទន្ទេញ អេសាយ ១:៨
- □ ចូរចែកចាយប្រាប់ទៅអ្នកដទៃឲ្យបានយ៉ាងតិចណាស់ម្នាក់អំពីការយាងមកវិញឆាប់ៗរបស់ព្រះយេស៊ូវ និង របៀបត្រៀមខ្លួនទទួលព្រះអង្គ។
(ខព្រះគម្ពីរផ្សេងទៀតស្តីពីការយាងមកវិញរបស់ព្រះយេស៊ូវ៖ សាការី ៣:១-៥; វិវរណៈ ៣:១៤-២១; កាឡាទី ៣:២៧)។

# ស្គាល់សញ្ញាសំគាល់

## ពួកសាវ័កនាសម័យចុងក្រោយ មេរៀន ទី៤



### សរសើរតម្កើងព្រះ និងអធិស្ឋាន

- តើលោកអ្នកមានអ្វីសរសើរតម្កើងព្រះទេ បន្ទាប់ពីយើងជួបគ្នាកន្លងមកនេះ?
- ថ្មីៗនេះតើមានអ្វីខ្លះដែលលោកអ្នកកំពុងព្រួយបារម្ភដែរទេ?
- សូមអធិស្ឋានសំរាប់សេចក្តីត្រូវការឲ្យគ្នាទៅវិញទៅមក។ ចូរសូមព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណបរិសុទ្ធស្ថិតក្នុងការជួបប្រជុំគ្នានេះ។

### ការរំឭកឡើងវិញ

- ចូរសូត្រខចងចាំជាមួយដៃគូម្នាក់ ឬពីរនាក់។
- តើលោកអ្នកបានរៀនអ្វីខ្លះកាលពីលើកមុន?
- តើមានការប្រែប្រួលអ្វីខ្លះក្នុងជីវិតរបស់អ្នក ដោយព្រោះសេចក្តីពិតដែលអ្នកបានរៀនពីមេរៀនមុននោះ?
- តើលោកអ្នកបានចែករំលែកអ្វីដែលបានរៀនកន្លងមកទៅកាន់នរណាខ្លះ?

### ការសិក្សាព្រះបន្ទូលរបស់ព្រះ

១) ចូរអាន លូកា ២១:២៥-៣១។ ដើមល្វាដែលមានផ្កាប្រាប់យើងថានឹងមានផ្លែឆាប់ៗ។ តើសញ្ញាសំគាល់អ្វីខ្លះដែលប្រាប់ថា ព្រះយេស៊ូវនឹងយាងមកវិញឆាប់ៗ?

២) ចូរអាន ម៉ាថាយ ២៤:៦-១៣។ តើមានសញ្ញាសំគាល់អ្វីផ្សេងទៀតអំពីការយាងមកឆាប់ៗរបស់ព្រះយេស៊ូវ?

៣) ចូរអាន ម៉ាថាយ ២៤:១៤។ តើសញ្ញាសម្គាល់មួយនៃការយាងមកវិញរបស់ព្រះយេស៊ូវ ដែលយើងអាចជួយឲ្យវាកើតឡើងបានគឺជាអ្វី?

៤) ចូរអាន ធីម៉ូថេទី២ ៣:១-៥។ តើសង្គមមនុស្សនឹងដូចជាអ្វីទៅវិញនៅសម័យចុងក្រោយ?

៥) តើមានអ្វីខ្លះដែលនាំឲ្យលោកអ្នកគិតថា សង្គមមនុស្សនៅសម័យសព្វថ្ងៃអាក្រក់ជាងពីមុន?

៦) ចូរអាន ម៉ាថាយ ២៤:៣៦-៣៩។ តើយើងអាចរៀនអ្វីខ្លះពីរឿងលោកណូអេនិងទឹកជំនន់ដែលនឹងជួយយើងរាល់គ្នាឲ្យត្រៀមខ្លួនជាស្រេចសំរាប់ការយាងមកវិញរបស់ព្រះយេស៊ូវ?

៧) តើលោកអ្នកគិតថា គ្រីស្ទានគួរគិត និយាយ និងរស់នៅដោយរបៀបណា ប្រសិនបើគាត់ពិតជាគិតថា ព្រះយេស៊ូវនឹងយាងមកក្នុងឆ្នាំនេះ?

៨) ចូរអាន ម៉ាថាយ ២៤:៤២-៤៤។ សំរាប់មនុស្សជាច្រើនថា ព្រះយេស៊ូវនឹងមកដល់ដូចជាចោរ។ ពួកគេនឹងបាត់បង់ទ្រព្យសម្បត្តិទាំងអស់នៃលោកនេះដែលពួកគេគិតថាសំខាន់។ ចុះលោកអ្នកវិញ អាចត្រៀមខ្លួនឲ្យរួចជាស្រេចចាំទទួលការយាងមកវិញរបស់ព្រះយេស៊ូវដោយរបៀបណា?

៩) ចូរអាន ភីលីព ១:៦; ៩-១១។ ការត្រៀមខ្លួនជាស្រេចសំរាប់ការយាងមកវិញរបស់ព្រះយេស៊ូវហាក់ដូច

ពិបាកនឹងធ្វើបានណាស់។ តើខព្រះគម្ពីរទាំងនេះអាចជួយលោកអ្នកឲ្យមានទំនុកចិត្តកាន់តែខ្លាំងឡើង ថែមទៀតដោយរបៀបណា?

១០) ចូរចំណាយពេលស្ងប់ស្ងាត់មួយរយៈពេល ដើម្បីគិតអំពីអ្វីដែលលោកអ្នកបានរៀនអំបាញ់មិញនេះ។ ចូរសូមឲ្យព្រះជាម្ចាស់បង្ហាញដល់លោកអ្នកបន្ថែមទៀតប្រសិនបើមានអ្វីដែលត្រូវផ្លាស់ប្ដូរនៅក្នុងចិត្តនិង ជីវិតរបស់លោកអ្នកដើម្បីត្រៀមខ្លួនជាស្រេចទទួលការយាងមកវិញរបស់ព្រះយេស៊ូវ?

## ចែកចាយ និងអធិស្ឋាន

□ នៅថ្ងៃនេះ តើលោកអ្នកបានរៀនអ្វីខ្លះដែលលោកអ្នកអាចនឹងយកទៅអនុវត្តនៅសប្ដាហ៍នេះ ដោយពឹងលើអំណាចរបស់ព្រះជាម្ចាស់?

□ ចូរពិភាក្សាអំពីសេចក្ដីត្រូវការក្នុងគ្រួសារ និងសហគមន៍ព្រមទាំងការប្ដេជ្ញាចិត្តរបស់លោកអ្នក ហើយសំរេចចិត្តថា តើមានអ្វីខ្លះដែលលោកអ្នកអាចជួយបាន?

□ សូមអធិស្ឋានឲ្យគ្នាទៅវិញទៅមក សំរាប់គ្រួសារនិងសហគមន៍របស់លោកអ្នកនៅពេលនេះចុះ។

## កិច្ចការពិសេស ឬកិច្ចអនុវត្តន៍

□ ចូរទន្ទេញ លូកា ២១:៣៤

□ ចូរចែកចាយប្រាប់ទៅអ្នកដទៃឲ្យបានយ៉ាងតិចណាស់ម្នាក់អំពីការយាងមកវិញឆាប់ៗរបស់ព្រះយេស៊ូវ និង របៀបត្រៀមខ្លួនទទួលព្រះអង្គ។

(ខព្រះគម្ពីរផ្សេងទៀតស្ដីពីការយាងមកវិញរបស់ព្រះយេស៊ូវ៖ យ៉ាកុប ៥:១-៨; ម៉ាកុស ១៣:៣-៣៧)។

# អ្នកបំរើស្មោះត្រង់ និង អ្នកបំរើអាក្រក់

## ពួកសាវ័កនាសម័យចុងក្រោយ មេរៀន ទី៥



### សរសើរតម្កើងព្រះ និងអធិស្ឋាន

- តើលោកអ្នកមានអ្វីសរសើរតម្កើងព្រះទេ បន្ទាប់ពីយើងជួបគ្នាកន្លងមកនេះ?
- ថ្មីៗនេះតើមានអ្វីខ្លះដែលលោកអ្នកកំពុងព្រួយបារម្ភដែរទេ?
- សូមអធិស្ឋានសំរាប់សេចក្ដីត្រូវការឲ្យគ្នាទៅវិញទៅមក។ ចូរសូមព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណបរិសុទ្ធស្ថិតក្នុងការជួបប្រជុំគ្នានេះ។

### ការរំឭកឡើងវិញ

- ចូរសូត្រខចងចាំជាមួយដៃគូម្នាក់ ឬពីរនាក់។
- តើលោកអ្នកបានរៀនអ្វីខ្លះកាលពីលើកមុន?
- តើមានការប្រែប្រួលអ្វីខ្លះក្នុងជីវិតរបស់អ្នក ដោយព្រោះសេចក្ដីពិតដែលអ្នកបានរៀនពីមេរៀនមុននោះ?
- តើលោកអ្នកបានចែករំលែកអ្វីដែលបានរៀនកន្លងមកទៅកាន់នរណាខ្លះ?

### ការសិក្សាព្រះបន្ទូលរបស់ព្រះ

១) សូមអានព្រះគម្ពីរ ម៉ាថាយ ២៤: ៤៥- ៥១. តើព្រះយេស៊ូវមានបន្ទូលយ៉ាងណាខ្លះអំពីអ្នកបំរើស្មោះត្រង់ និងអ្នកបំរើអាក្រក់?

២) តើចៅហ្វាយ ហើយនិង អ្នកបំរើ ក្នុងសាច់រឿងនេះតំណាងអោយអ្នកណា?

៣) តើនឹងមានអ្វីកើតឡើងដល់អស់អ្នកដែលប្រកាសខ្លួនថាជាគ្រីស្ទាន ប៉ុន្តែ រស់នៅតាមបែបអាត្មានិយម និងប្រព្រឹត្តិមិនល្អដាក់អ្នកដទៃនៅពេលព្រះយេស៊ូវយាងមក?

៤) សូមអានព្រះគម្ពីរ អេភេសូរ ៤:១- ៦. សូមពណ៌នាអំពីអ្វីដែលជាលក្ខណៈនៃការរួបរួមគ្នានៅក្នុងពួកជំនុំ!

៥) សូមអានព្រះគម្ពីរ អេភេសូរ ៤:១៥, ១៦, ២៥-៣២. តើព្រះគម្ពីរបង្រៀនអ្វីខ្លះដែលយើងគួរធ្វើនិងមិនគួរធ្វើដាក់គ្នា?

៦) សូមអានព្រះគម្ពីរ អេភេសូរ ៤:២២-២៤. យើងទាំងអស់គ្នាកំពុងតែខំប្រឹងឲ្យបាននូវភាពអត់ធ្មត់ និង ចិត្តសប្បុរស។ តើយើងអាចក្លាយជាមនុស្សដែលមានសេចក្តីស្រលាញ់ពិតបានដោយរបៀបណា?

៧) សូមអានព្រះគម្ពីរ ហេព្រើរ ១០:២៤-២៥. ជាពិសេសតើយើងគួរតែធ្វើអ្វីចំពោះគ្នាទៅវិញទៅមក តាម ដែលឃើញថាការយាងមកយ៉ាងឆាប់របស់ព្រះយេស៊ូជិតមកដល់?

៨) សូមអានព្រះគម្ពីរ ហេព្រើរ ១០:២១-២៣. តើព្រះយេស៊ូវដ៏ជាសំដេចសង្ឃរបស់យើងអាចធ្វើអ្វីដើម្បីជួយ ឲ្យយើងស្រលាញ់គ្នាទៅវិញទៅមកបាន?

៩) សូមអានព្រះគម្ពីរ យ៉ូហាន ១៧:២០-២៣.ប្រសិនបើយើងទាំងអស់គ្នារួបរួមគ្នា តើមនុស្សនៅលើផែនដី នេះនឹងជឿលើអ្វី?

១០) សូមអានព្រះគម្ពីរ យ៉ូហាន ១៧:១៥-១៧. ដោយយោងតាមព្រះបន្ទូលរបស់ព្រះយេស៊ូវ តើយើងអាច មានការរួបរួមគ្នាដ៏អស្ចារ្យនេះបានដោយរបៀបណា?

១១) សូមចំនាយពេលដ៏ស្ងាត់ស្ងៀមមួយដើម្បីគិតពិចារណានូវអ្វីដែលអ្នកបានរៀនរួចមកហើយ។ បន្ទាប់ មកចូរទូលសូមឲ្យព្រះជាម្ចាស់ទ្រង់បើកសម្តែងនូវអ្វីៗដែលមាននៅក្នុងចិត្តនិងជីវិតរបស់អ្នកដែលត្រូវ ការផ្លាស់ប្តូរ ដើម្បីជួយឲ្យអ្នកត្រៀមខ្លួនរួចជាស្រេចសំរាប់ការយាងមករបស់ព្រះយេស៊ូវ?

## ចែកចាយ និងអធិស្ឋាន

- □ នៅថ្ងៃនេះ តើលោកអ្នកបានរៀនអ្វីខ្លះដែលលោកអ្នកអាចនឹងយកទៅអនុវត្តនៅសប្តាហ៍នេះ ដោយពឹងលើអំណាចរបស់ព្រះជាម្ចាស់?
- □ ចូរពិភាក្សាអំពីសេចក្តីត្រូវការក្នុងគ្រួសារ និងសហគមន៍ព្រមទាំងការប្តេជ្ញាចិត្តរបស់លោកអ្នក ហើយសំរេចចិត្តថា តើមានអ្វីខ្លះដែលលោកអ្នកអាចជួយបាន?
- □ សូមអធិស្ឋានឲ្យគ្នាទៅវិញទៅមក សំរាប់គ្រួសារនិងសហគមន៍របស់លោកអ្នកនៅពេលនេះចុះ។

## កិច្ចការពិសេស ឬកិច្ចអនុវត្តន៍

- □ ខចងចាំ, គម្ពីរ យ៉ូហាន ១៧:២៣
- □ ចូរចែកចាយប្រាប់ទៅអ្នកដទៃឲ្យបានយ៉ាងតិចណាស់ម្នាក់អំពីការយាងមកវិញឆាប់ៗរបស់ព្រះ យេស៊ូវ និង របៀបត្រៀមខ្លួនទទួលព្រះអង្គ។

( សូមអានបន្ថែមអំពីការយាងមករបស់ព្រះយេស៊ូវនៅក្នុងព្រះគម្ពីរៈ ភីលីព ២:១-៨, កូរិនថូសទី១ ១៣:១-៨, យ៉ូហាន ១៣:១-១៧)

# ចូរបំពេញប្រេងក្នុងចង្កៀងរបស់អ្នក

## ពួកសាវ័កនាសម័យចុងក្រោយ មេរៀន ទី៦



### សរសើរតម្កើងព្រះ និងអធិស្ឋាន

- តើលោកអ្នកមានអ្វីសរសើរតម្កើងព្រះទេ បន្ទាប់ពីយើងជួបគ្នាកន្លងមកនេះ?
- ថ្មីៗនេះតើមានអ្វីខ្លះដែលលោកអ្នកកំពុងព្រួយបារម្ភដែរទេ?
- សូមអធិស្ឋានសំរាប់សេចក្តីត្រូវការឲ្យគ្នាទៅវិញទៅមក។ ចូរសូមព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណបរិសុទ្ធស្ថិតក្នុងការជួបប្រជុំគ្នានេះ។

### ការរំឭកឡើងវិញ

- ចូរសូត្រខចងចាំជាមួយដៃគូម្នាក់ ឬពីរនាក់។
- តើលោកអ្នកបានរៀនអ្វីខ្លះកាលពីលើកមុន?
- តើមានការប្រែប្រួលអ្វីខ្លះក្នុងជីវិតរបស់អ្នក ដោយព្រោះសេចក្តីពិតដែលអ្នកបានរៀនពីមេរៀនមុននោះ?
- តើលោកអ្នកបានចែករំលែកអ្វីដែលបានរៀនកន្លងមកទៅកាន់នរណាខ្លះ?

### ការសិក្សាព្រះបន្ទូលរបស់ព្រះ

១) សូមអានព្រះគម្ពីរ ម៉ាថាយ ២៥:១-១៣. តើប្តី(កូនកំលោះ) ដែលក្រមកដល់នោះតំណាងឲ្យអ្នកណា?
២) សូមអានព្រះគម្ពីរ កូរិនថូសទី២ ១១:២. តើស្រីព្រហ្មចារី៥នាក់ដែលមានគំនិត និង ៥នាក់ដែលឥតគំនិតនោះតំណាងឲ្យអ្នកណា?
៣) សូមអានព្រះគម្ពីរ ទំនុកដំកើង ១១៩:១០៥. នៅក្នុងព្រះគម្ពីរ តើចង្កៀងតំណាងឲ្យអ្វី?
៤) សូមអានព្រះគម្ពីរ សាការី ៤:១-៦. មនុស្សនៅសម័យព្រះគម្ពីរសញ្ញាចាស់ បានយកផ្លែអូលីវមកគាបយកប្រេង។ ពួកគេចាក់ប្រេងក្នុងចង្កៀងហើយអុជវា។ នៅក្នុងព្រះគម្ពីរតើប្រេងតំណាងឲ្យអ្វី?
៥) សូមអានព្រះគម្ពីរ ម៉ាថាយ ៧:២១-២៣. តើស្រីព្រហ្មចារីដែលឥតគំនិតកាន់តែចង្កៀងឥតត្រៀមប្រេងទុកនោះតំណាងឲ្យគ្រីស្ទានប្រភេទណា? ហើយតើកូនកំលោះបាននិយាយថា៖ «ខ្ញុំមិនស្គាល់អ្នករាល់គ្នាទេ!» ចំពោះអ្នកណា?

៦) សូមអានព្រះគម្ពីរ ម៉ាថាយ ៥:១៦. តើជីវិតរបស់អ្នកនឹងទៅជាយ៉ាងណា ប្រសិនបើអ្នកអានព្រះបន្ទូលព្រះហើយនិងអធិស្ឋានសូមយាងព្រះវិញ្ញាណបរិសុទ្ធមកគង់ជាមួយអ្នកនោះ?

៧) សូមអានព្រះគម្ពីរ កាឡាទី ៥:១៦, ១៩-២១. តើសេចក្តីប៉ងប្រាថ្នាបែបណាដែលមិនគួរឲ្យមាននៅក្នុងគ្រួសារ និងពួកជំនុំរបស់យើង?

៨) សូមអានព្រះគម្ពីរ កាឡាទី ៥:២២ -២៣។ ប្រសិនបើព្រះវិញ្ញាណបរិសុទ្ធគង់ក្នុងយើងរាល់គ្នាមែន តើសេចក្តីប៉ងប្រាថ្នាអ្វីដែលគួរនឹងចង់មាននៅក្នុងគ្រួសារ ពួកជំនុំ កន្លែងធ្វើការ និង អ្នកជិតខាងរបស់យើង?

៩) សូមអានព្រះគម្ពីរ លូកា ១១:៩ -១០, ១៣. តើយើងអាចធ្វើយ៉ាងណាដើម្បីឲ្យជីវិតរបស់យើងបានពោពេញទៅដោយព្រះវិញ្ញាណបរិសុទ្ធក្នុងការត្រៀមខ្លួនជាស្រេចសំរាប់ការយាងមករបស់ព្រះយេស៊ូវ?

១០) សូមចំនាយពេលដ៏ស្ងាត់ស្ងៀមមួយដើម្បីគិតពិចារណានូវអ្វីដែលអ្នកបានរៀនរួចមកហើយ។ បន្ទាប់មកចូរទូលសូមឲ្យព្រះជាម្ចាស់ទ្រង់បើកសម្តែងនូវអ្វីៗដែលមាននៅក្នុងចិត្តនិងជីវិតរបស់អ្នកដែលត្រូវការផ្លាស់ប្តូរ ដើម្បីជួយឲ្យអ្នកត្រៀមខ្លួនរួចជាស្រេចសំរាប់ការយាងមករបស់ព្រះយេស៊ូវ?

## ចែកចាយ និងអធិស្ឋាន

- □ នៅថ្ងៃនេះ តើលោកអ្នកបានរៀនអ្វីខ្លះដែលលោកអ្នកអាចនឹងយកទៅអនុវត្តនៅសប្តាហ៍នេះដោយពឹងលើអំណាចរបស់ព្រះជាម្ចាស់?
- □ ចូរពិភាក្សាអំពីសេចក្តីត្រូវការក្នុងគ្រួសារ និងសហគមន៍ព្រមទាំងការប្តេជ្ញាចិត្តរបស់លោកអ្នក ហើយសំរេចចិត្តថា តើមានអ្វីខ្លះដែលលោកអ្នកអាចជួយបាន?
- □ សូមអធិស្ឋានឲ្យគ្នាទៅវិញទៅមក សំរាប់គ្រួសារនិងសហគមន៍របស់លោកអ្នកនៅពេលនេះចុះ។

## កិច្ចការពិសេស ឬកិច្ចអនុវត្តន៍

- □ ខចងចាំ, គម្ពីរ *លូកា ១១:១៣*
- □ ចូរចែកចាយប្រាប់ទៅអ្នកដទៃឲ្យបានយ៉ាងតិចណាស់ម្នាក់អំពីការយាងមកវិញឆាប់ៗរបស់ព្រះយេស៊ូវ និង របៀបត្រៀមខ្លួនទទួលព្រះអង្គ។

( សូមអានបន្ថែមអំពីការយាងមករបស់ព្រះយេស៊ូវនៅក្នុងព្រះគម្ពីរៈ ម៉ាថាយ ៥:១៤-១៦, ទីតុស ៣:៤-៨, រ៉ូម ៨:១-១៧)

# ចូរចែករំលែកនូវអ្វីដែលអ្នកមាន

## ពួកសាវ័កនាសម័យចុងក្រោយ មេរៀន ទី៧



## សរសើរតម្កើងព្រះ និងអធិស្ឋាន

- តើលោកអ្នកមានអ្វីសរសើរតម្កើងព្រះទេ បន្ទាប់ពីយើងជួបគ្នាកន្លងមកនេះ?
- ថ្មីៗនេះតើមានអ្វីខ្លះដែលលោកអ្នកកំពុងព្រួយបារម្ភដែរទេ?
- សូមអធិស្ឋានសំរាប់សេចក្តីត្រូវការឲ្យគ្នាទៅវិញទៅមក។ ចូរសូមព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណបរិសុទ្ធស្ថិតក្នុងការជួបប្រជុំគ្នានេះ។

## ការរំឭកឡើងវិញ

- ចូរសូត្រខចងចាំជាមួយដៃគូម្នាក់ ឬពីរនាក់។
- តើលោកអ្នកបានរៀនអ្វីខ្លះកាលពីលើកមុន?
- តើមានការប្រែប្រួលអ្វីខ្លះក្នុងជីវិតរបស់អ្នក ដោយព្រោះសេចក្តីពិតដែលអ្នកបានរៀនពីមេរៀនមុននោះ?
- តើលោកអ្នកបានចែករំលែកអ្វីដែលបានរៀនកន្លងមកទៅកាន់នរណាខ្លះ?

## ការសិក្សាព្រះបន្ទូលរបស់ព្រះ

១) សូមអានព្រះគម្ពីរ ម៉ាថាយ ២៥:១៤ -៣០. តើបុរសជាចៅហ្វាយដែលចេញដំណើរទៅស្រុកឆ្ងាយរួចត្រឡប់មកវិញនោះជានរណា? ហើយតើអ្នកបំរើរបស់គាត់ទាំងនោះតំណាងឲ្យអ្នកណា?

២) តើប្រាក់ដែលនៅក្នុងរឿងប្រៀបប្រដូចនេះតំណាងឲ្យអ្វី?

៣) តើមានអ្វីកើតឡើងចំពោះអ្នកបំរើដែលយកប្រាក់ទៅជួញបានចំនេញប្រាក់ឲ្យចៅហ្វាយហើយនិង អ្នកបំរើដែលមិនបានយកប្រាក់ទៅជួញអ្វីសោះ?

៤) សូមអានព្រះគម្ពីរ ម៉ាថាយ ២២:៣៧ -៣៨. ចូររិះរកវិធីណាដែលយើងអាចប្រើអំណោយទានដែលព្រះបានប្រទានដល់យើងឲ្យបានល្អសមរម្យ? ព្រះជាម្ចាស់បានប្រទានឲ្យអ្នកមានចិត្ត គំនិត និង រូបកាយដែលអាចស្គាល់ និង ស្រលាញ់ទ្រង់បាន។ តើអ្នកមានវិធីអ្វីដែលធ្វើឲ្យគំនិតនិងរូបកាយរបស់អ្នកអាចបំរើទ្រង់កាន់តែល្អប្រសើរឡើងបាន?

៥) សូមអានព្រះគម្ពីរ កូរិនថូសទី១ ១២:៤ -១១. តាមរយៈព្រះវិញ្ញាណបរិសុទ្ធព្រះជាម្ចាស់បានប្រទាន អំណោយទាននៃព្រះវិញ្ញាណដល់អស់អ្នកដែលបានសំរេចចិត្តជឿនិងដើរតាមព្រះយេស៊ូវ។ តើអ្នកគិតថាព្រះបានប្រទានឲ្យអ្នកមានសមត្ថភាពអ្វីក្នុងការជួយអ្នកដទៃ? ហើយតើអ្នកដទៃគិតថាព្រះបានប្រទានអ្វីដល់អ្នក?

៦) សូមអានព្រះគម្ពីរ អេភេសូរ ៥:១-៧, ១៥-១៦. មនុស្សគ្រប់រូបមានពេល ២៤ម៉ោងក្នុងមួយថ្ងៃដូចៗគ្នា។ ហើយនេះគឺជាអំណោយ(ព្រះពរ)មកពីព្រះជាម្ចាស់ផងដែរ។ ដូចដែលអ្នកដឹងស្រាប់ហើយថាព្រះយេស៊ូវនឹងយាងមកឆាប់ៗនេះ អញ្ចឹងតើមានរឿងឥតប្រយោជន៍អ្វីខ្លះដែលអ្នកគួរតែឈប់ប្រព្រឹត្ត(ធ្វើ) ហើយងាកបែរមកធ្វើអ្វីដែលមានប្រយោជន៍ជំនួសវិញ?

៧) សូមអានព្រះគម្ពីរ លូកា ៦:៣៨. នៅក្នុងរឿងប្រៀបប្រដូចនេះ យើងឃើញថាអ្នកដែលមានត្រូវបានផ្តល់ឲ្យបន្ថែមទៀត។ គ្រប់ទាំងទ្រព្យសម្បត្តិ លុយកាក់ និង អ្វីៗដែលយើងមានសុទ្ធតែជាអំណោយមកពីព្រះជាម្ចាស់ទាំងអស់ផងដែរ។
តើព្រះជាម្ចាស់បានសន្យាអ្វីចំពោះអស់អ្នកដែលមានចិត្តសប្បុរសក្នុងការជួយអ្នកដទៃនិង ក្នុងការថ្វាយដង្វាយដប់ហូតមួយ និង ដង្វាយសទ្ធាដល់ព្រះអម្ចាស់?

៨) សូមអានព្រះគម្ពីរ កូរិនថូសទី២ ៥:១៤ -១៥, ១៧. នៅជុំវិញយើងរាល់គ្នាមានសុទ្ធតែមនុស្សអាត្មានិយមដែលធ្វើគ្រប់យ៉ាងដើម្បីតែខ្លួនឯង។ ព្រះយេស៊ូវបានត្រាស់ហៅយើងឲ្យរស់នៅផ្ទុយពីមនុស្សទាំងនោះ គឺថាយើងត្រូវតែប្រើអំណោយទាននិងព្រះពរដែលយើងមានសំរាប់បំរើព្រះនិងអ្នកដទៃវិញ។ តើព្រះយេស៊ូវទ្រង់បានធ្វើអ្វីខ្លះដើម្បីជួយយើងឲ្យរស់នៅដោយមិនកំណាញ់?

៩) សូមចំនាយពេលដ៏ស្ងាត់ស្ងៀមមួយដើម្បីគិតពិចារណានូវអ្វីដែលអ្នកបានរៀនរួចមកហើយ។ បន្ទាប់មកចូរទូលសូមឲ្យព្រះជាម្ចាស់ទ្រង់បើកសម្តែងនូវអ្វីៗដែលមាននៅក្នុងចិត្តនិងជីវិតរបស់អ្នកដែលត្រូវការផ្លាស់ប្តូរដើម្បីជួយឲ្យអ្នកត្រៀមខ្លួនរួចជាស្រេចសំរាប់ការយាងមករបស់ព្រះយេស៊ូវ?

## ចែកចាយ និងអធិស្ឋាន

- □ នៅថ្ងៃនេះ តើលោកអ្នកបានរៀនអ្វីខ្លះដែលលោកអ្នកអាចនឹងយកទៅអនុវត្តនៅសប្តាហ៍នេះដោយពឹងលើអំណាចរបស់ព្រះជាម្ចាស់?
- □ ចូរពិភាក្សាអំពីសេចក្តីត្រូវការក្នុងគ្រួសារ និងសហគមន៍ព្រមទាំងការប្តេជ្ញាចិត្តរបស់លោកអ្នក ហើយសំរេចចិត្តថា តើមានអ្វីខ្លះដែលលោកអ្នកអាចជួយបាន?
- □ សូមអធិស្ឋានឲ្យគ្នាទៅវិញទៅមក សំរាប់គ្រួសារនិងសហគមន៍របស់លោកអ្នកនៅពេលនេះចុះ។

## កិច្ចការពិសេស ឬកិច្ចអនុវត្តន៍

- □ ខចងចាំ, គម្ពីរ កូរិនថូសទី២ ៩:៨
- □ ចូរចែកចាយប្រាប់ទៅអ្នកដទៃឲ្យបានយ៉ាងតិចណាស់ម្នាក់អំពីការយាងមកវិញឆាប់ៗរបស់ព្រះយេស៊ូវ និង របៀបត្រៀមខ្លួនទទួលព្រះអង្គ។

( សូមអានបន្ថែមអំពីការយាងមករបស់ព្រះយេស៊ូវនៅក្នុងព្រះគម្ពីរ៖ យ៉ូហានទី១ ២:១៥-១៧,
កូរិនថូសទី១ ១០:៦-១៣.)

# ចូរធ្វើល្អចំពោះអស់អ្នកតូចទាប

## ពួកសាវ័កនាសម័យចុងក្រោយ មេរៀន ទី៨



## សរសើរតម្កើងព្រះ និងអធិស្ឋាន

- តើលោកអ្នកមានអ្វីសរសើរតម្កើងព្រះទេ បន្ទាប់ពីយើងជួបគ្នាកន្លងមកនេះ?
- ថ្មីៗនេះតើមានអ្វីខ្លះដែលលោកអ្នកកំពុងព្រួយបារម្ភដែរទេ?
- សូមអធិស្ឋានសំរាប់សេចក្តីត្រូវការឲ្យគ្នាទៅវិញទៅមក។ ចូរសូមព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណបរិសុទ្ធស្ថិតក្នុងការជួបប្រជុំគ្នានេះ។

## ការរំឭកឡើងវិញ

- ចូរសូត្រខចងចាំជាមួយដៃគូម្នាក់ ឬពីរនាក់។
- តើលោកអ្នកបានរៀនអ្វីខ្លះកាលពីលើកមុន?
- តើមានការប្រែប្រួលអ្វីខ្លះក្នុងជីវិតរបស់អ្នក ដោយព្រោះសេចក្តីពិតដែលអ្នកបានរៀនពីមេរៀនមុននោះ?
- តើលោកអ្នកបានចែករំលែកអ្វីដែលបានរៀនកន្លងមកទៅកាន់នរណាខ្លះ?

## ការសិក្សាព្រះបន្ទូលរបស់ព្រះ

១) សូមអានព្រះគម្ពីរ ម៉ាថាយ ២៥:៣១ -៣៦. នៅពេលដែលព្រះយេស៊ូវធ្វើការជំនុំជំរះចំពោះគ្រប់សាសន៍ទាំងអស់ , តើមនុស្សប្រភេទណាដែលព្រះទ្រង់ត្រាស់ហៅឲ្យចូលមកទទួលចំនែកនៅនគរស្ថានសួគ៌?

២) សូមចែកចាយអំពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់អ្នក កាលពីពេលដែលអ្នកធ្លាប់ខ្វះខាត រឺ កំពុងតែឈឺ ហើយស្រាប់តែមានមនុស្សបានមកជួយអ្នក។ តើអ្នកមានអារម្មណ៍យ៉ាងណាដែរពេលនោះ?

៣) សូមអានព្រះគម្ពីរ ម៉ាថាយ ២៥:៣៧ -៤០. «ការអ្វីដែលអ្នករាល់គ្នាធ្វើដល់អ្នកតូចបំផុតក្នុងលោកិយនេះ គឺឈ្មោះថាធ្វើដល់ខ្ញុំដែរ!» តើអ្នកគិតថាហេតុអ្វីបានជាព្រះយេស៊ូវមានបន្ទូលដូច្នេះ?

៤ ) សូមអានព្រះគម្ពីរ ម៉ាថាយ ២៥:៤១ -៤៦. តាមធម្មតាមនុស្សភាគច្រើនគិតថាព្រះជាម្ចាស់នឹងបំផ្លាញដល់មនុស្សអាក្រក់ដែលបានធ្វើឲ្យមានបញ្ហាជាច្រើនកើតឡើង ដូចជា កាប់សំលាប់ លួចប្លន់ជាដើម។ តើព្រះយេស៊ូវមានបន្ទូលដូចម្តេចខ្លះអំពីមូលហេតុដែលបណ្តាលឲ្យមនុស្សជាច្រើននឹងត្រូវបាត់បង់?

៥) សូមអានព្រះគម្ពីរ យ៉ាកុប ២:២៧. តើការយកចិត្តទុកដាក់ចំពោះក្មេងកំព្រា និង ស្ត្រីមេម៉ាយវាសំខាន់ប៉ុនណាទៅបានជាព្រះជាម្ចាស់ទ្រង់សព្វព្រះហឫទ័យឲ្យយើងធ្វើការនោះ?

៦) សូមអានព្រះគម្ពីរ អេសាយ ៥៨:៦ -៩, ១១។ តើព្រះទ្រង់បានសន្យាអ្វីចំពោះយើងប្រសិនបើយើងជួយដល់អស់អ្នកដែលរងទុក្ខនោះ?

៧) សូមអានព្រះគម្ពីរ លូកា ៦:៣០ និងថែស្សាឡូនីចទី២ ៣:១០ -១៣ ។ តើមានវិធីដ៏ល្អបំផុតអ្វីខ្លះ ដើម្បីជួយដល់អស់អ្នកដែលក្រក្រី និងអ្នកសុំទានទាំងនោះ?

៨) សូមអានព្រះគម្ពីរ កូរិនថូសទី២ ៤:៧ -១៥. ជូនកាលវាពិបាកខ្លាំងណាស់ក្នុងការជួយដល់មនុស្សដែលមានបញ្ហាច្រើននោះ។ តើអ្នកមានកំលាំងចិត្តអ្វីដែលអាចជួយឲ្យអ្នកធ្វើការនេះបាន?

៩) សូមចំនាយពេលដ៏ស្ងាត់ស្ងៀមមួយដើម្បីគិតពិចារណានូវអ្វីដែលអ្នកបានរៀនរួចមកហើយ។ បន្ទាប់មកចូរទូលសូមឲ្យព្រះជាម្ចាស់ទ្រង់បើកសម្ដែងនូវអ្វីៗដែលមាននៅក្នុងចិត្តនិងជីវិតរបស់អ្នកដែលត្រូវការផ្លាស់ប្ដូរ ដើម្បីជួយឲ្យអ្នកត្រៀមខ្លួនរួចជាស្រេចសំរាប់ការយាងមករបស់ព្រះយេស៊ូវ?

## ចែកចាយ និងអធិស្ឋាន

- □ នៅថ្ងៃនេះ តើលោកអ្នកបានរៀនអ្វីខ្លះដែលលោកអ្នកអាចនឹងយកទៅអនុវត្តនៅសប្ដាហ៍នេះដោយពឹងលើអំណាចរបស់ព្រះជាម្ចាស់?
- □ ចូរពិភាក្សាអំពីសេចក្ដីត្រូវការក្នុងគ្រួសារ និងសហគមន៍ព្រមទាំងការប្ដេជ្ញាចិត្តរបស់លោកអ្នក ហើយសំរេចចិត្តថា តើមានអ្វីខ្លះដែលលោកអ្នកអាចជួយបាន?
- □ សូមអធិស្ឋានឲ្យគ្នាទៅវិញទៅមក សំរាប់គ្រួសារនិងសហគមន៍របស់លោកអ្នកនៅពេលនេះចុះ។

## កិច្ចការពិសេស ឬកិច្ចអនុវត្តន៍

- □ ខចងចាំ, គម្ពីរ ម៉ាថាយ ២៥:៤០
- □ ចូរចែកចាយប្រាប់ទៅអ្នកដទៃឲ្យបានយ៉ាងតិចណាស់ម្នាក់អំពីការយាងមកវិញឆាប់ៗរបស់ព្រះយេស៊ូវ និង របៀបត្រៀមខ្លួនទទួលព្រះអង្គ។

( សូមអានបន្ថែមអំពីការយាងមករបស់ព្រះយេស៊ូវនៅក្នុងព្រះគម្ពីរៈ យ៉ូហានទី១ ៤:១៥-១៩, យ៉ូហាន ១៣:៣៤-៣៥.)

# ត្រូវសរសើរដំកើងព្រះគ្រប់រាល់ទាំងអ្វីដែលអ្នកបរិភោគ រឺផឹក

## ពួកសាវ័កនាសម័យចុងក្រោយ មេរៀន ទី៩



## សរសើរតម្កើងព្រះ និងអធិស្ឋាន

- តើលោកអ្នកមានអ្វីសរសើរតម្កើងព្រះទេ បន្ទាប់ពីយើងជួបគ្នាកន្លងមកនេះ?
- ថ្មីៗនេះតើមានអ្វីខ្លះដែលលោកអ្នកកំពុងព្រួយបារម្ភដែរទេ?
- សូមអធិស្ឋានសំរាប់សេចក្តីត្រូវការឲ្យគ្នាទៅវិញទៅមក។ ចូរសូមព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណបរិសុទ្ធស្ថិតក្នុងការជួបប្រជុំគ្នានេះ។

## ការរំឭកឡើងវិញ

- ចូរសូត្រខចងចាំជាមួយដៃគូម្នាក់ ឬពីរនាក់។
- តើលោកអ្នកបានរៀនអ្វីខ្លះកាលពីលើកមុន?
- តើមានការប្រែប្រួលអ្វីខ្លះក្នុងជីវិតរបស់អ្នក ដោយព្រោះសេចក្តីពិតដែលអ្នកបានរៀនពីមេរៀនមុននោះ?
- តើលោកអ្នកបានចែករំលែកអ្វីដែលបានរៀនកន្លងមកទៅកាន់នរណាខ្លះ?

## ការសិក្សាព្រះបន្ទូលរបស់ព្រះ

១) សូមអានព្រះគម្ពីរ ដានីយ៉ែល១:១-១៤។ យុវជនទាំងបួននាក់នេះសុទ្ធតែជាអ្នកគោរពប្រតិបត្តិដល់ព្រះដ៏ពិត ប៉ុន្តែពួកគេបានក្លាយជាអ្នកទោសនៃអាណាចក្រដ៏ខ្លាំងក្លាមួយទៅវិញ។ យ៉ាងណាក៏ដោយ ពួកគេទាំងអស់គ្នាត្រូវបានផ្តល់ឱកាសដើម្បីធ្វើការសិក្សានិងបំរើស្តេចនៃអាណាចក្រនោះ។ មិនត្រឹមតែប៉ុណ្ណោះស្តេចអាណាចក្របានផ្តល់អាហារ និងស្រាដែលទ្រង់សោយលើតុរបស់ទ្រង់ មកកាន់ពួកគេដើម្បីបរិភោគ ដាក់ស្តែងចំណីអាហារទាំងនោះគឺជាសំនែនដែលបានថ្វាយដល់ព្រះដ៏ច្រើនរបស់ស្តេច។ ដូច្នេះតើដានីយ៉ែលមានការឆ្លើយតបយ៉ាងដូចម្តេចចំពោះសេចក្តីល្បួងដ៏ធំនោះ?

២) សូមអានព្រះគម្ពីរ ដានីយ៉ែល១:១៥-២១។ តើព្រះបានប្រទានពរអ្វីខ្លះដល់ដានីយ៉ែលហើយនិងមិត្តភ័ក្ត្ររបស់គាត់ ដោយពួកគេបានជ្រើសរើសបរិភោគតែបន្លែ ផ្លែឈើ និងគ្រាប់ធញ្ញជាតិជំនួសអោយសាច់សត្វនិងស្រាទៅវិញ?

៣) សូមអានព្រះគម្ពីរ សុភាសិត ២៣:២៩-៣៣។ តើព្រះគម្ពីរបានណែនាំថានឹងមានអ្វីកើតឡើងខ្លះ នៅពេលយើងផឹកស្រា?

៤)  សូមអានព្រះគម្ពីរ លោកុប្បត្តិ១:២៩ និង៣:១៨។ តើមានចំណីអាហារអ្វីខ្លះដែលព្រះបានផ្តល់អោយមនុស្សបរិភោគ?
៥)  សូមអានព្រះគម្ពីរ លេវីវិន័យ ១១:១-១២។ បន្ទាប់ពីទឹកជំនន់បានជន់លិចផែនដី ព្រះជាម្ចាស់បានអនុញ្ញាតិអោយមនុស្សបរិភោគសាច់សត្វជាចំណីអាហារ ប៉ុន្តែចំណីអាហារទាំងនោះបានកាត់បន្ថយអាយុរបស់មនុស្សយ៉ាងច្រើន។ ប៉ុន្តែ ព្រះបានបង្គាប់អោយមនុស្សបរិភោគសាច់សត្វតែមួយចំនួនប៉ុណ្ណោះ។ តើមានសាច់សត្វអ្វីខ្លះដែលព្រះទ្រង់អនុញ្ញាតិអោយមនុស្សលោកបរិភោគ?
៦)  សូមអានព្រះគម្ពីរ និក្ខមនំ១៥:២៦។ តើព្រះជាម្ចាស់បានប្រទានសេចក្តីសន្យាយ៉ាងដូចម្តេចខ្លះដល់អស់ អ្នកណាដែលបានកាន់តាមច្បាប់សុខភាព និងក្រឹត្យក្រមសីលធម៌របស់ទ្រង់?
៧)  សូមអានព្រះគម្ពីរ កូរិនថូសទី១ ៦:១៩-២០។ ដោយរាងកាយរបស់យើងគឺជាព្រះវិហាររបស់ព្រះ យើងគួរតែថែរក្សាវាអោយមានអនាម័យ និងសុខភាពល្អ ហើយមិនត្រូវចោលសំរាមទៅក្នុងរាងកាយនោះឡើយ។ តើអ្នកបានអនុវត្តការថែរក្សាសុខភាពរាងកាយរបស់អ្នកអោយមានសភាពរឹងមាំយ៉ាងដូចម្តេចខ្លះ ដើម្បីបំពេញកិច្ចការថ្វាយព្រះអម្ចាស់ ដូចដែលលោកដានីយ៉ែលនិងមិត្តភ័ក្រ្តទាំងបីរបស់គាត់បានធ្វើ?
៨)  សូមអានព្រះគម្ពីរ ម៉ាកុស១២:២៩-៣១។ នៅពេលដែលអ្នកមិនបានអនុវត្តការថែរក្សាសុខភាពអោយបានល្អ រហូតជាប់មានជំងឺផ្សេងៗ តើអ្នកយល់ថាវាមានផលបះពាល់អ្វីខ្លះដល់គំនិតស្មារតី និង កំលាំងរបស់អ្នក ដើម្បីស្រលាញ់ព្រះ និងមនុស្សដទៃទៀត?
៩)  សូមអានព្រះគម្ពីរ កូរិនថូសទី១ ១០:៦-៧, ១១-១៣។ វាហាក់បីដូចជាពិបាកបន្តិច ដែលយើងត្រូវជ្រើស យកចំណីអាហារណាដែលទ្រទ្រង់សុខភាព ប៉ុន្តែខុសរសជាតិពីអ្វីដែលយើងចូលចិត្តបរិភោគ ហើយបំផ្លាញសុខភាពទៅវិញ។ តើព្រះទ្រង់បានផ្តល់នូវសេចក្តីសន្យាអ្វី ដើម្បីជាជំនួយដល់យើងរាល់គ្នានៅគ្រាដែលជួបសេចក្តីល្បួង?
១០)  សូមរកពេលវេលាស្ងប់ស្ងាត់មួយ ដើម្បីសញ្ជឹងគិតឡើងវិញនូវអ្វីដែលអ្នកបានរៀនមុននេះ។ ចូរទូលសូម ដល់ព្រះអម្ចាស់យេស៊ូវគ្រិស្តអោយទ្រង់បានបំផ្លាស់បំប្រែនូវបញ្ហាដែលកើតមានឡើងនៅក្នុងចិត្ត និងជីវិតរបស់អ្នក ប្រយោជន៍អោយអ្នកបានត្រៀមខ្លួនរួចជាស្រេច ក្នុងការរង់ចាំនូវការយាងវិលត្រលប់មកវិញ របស់ទ្រង់។

## ចែកចាយ និងអធិស្ឋាន

- ☐ នៅថ្ងៃនេះ តើលោកអ្នកបានរៀនអ្វីខ្លះដែលលោកអ្នកអាចនឹងយកទៅអនុវត្តនៅសប្តាហ៍នេះដោយពឹងលើអំណាចរបស់ព្រះជាម្ចាស់?
- ☐ ចូរពិភាក្សាអំពីសេចក្តីត្រូវការក្នុងគ្រួសារ និងសហគមន៍ព្រមទាំងការប្តេជ្ញាចិត្តរបស់លោកអ្នក ហើយសំរេចចិត្តថា តើមានអ្វីខ្លះដែលលោកអ្នកអាចជួយបាន?
- ☐ សូមអធិស្ឋានឲ្យគ្នាទៅវិញទៅមក សំរាប់គ្រួសារនិងសហគមន៍របស់លោកអ្នកនៅពេលឥឡូវនេះ។

## កិច្ចការពិសេស ឬកិច្ចអនុវត្តន៍

- ☐ សូមទន្ទេញខព្រះគម្ពីរ កូរិនថូសទី១ ១០:៣១។
- ☐ ចូរចែកចាយប្រាប់ទៅអ្នកដទៃឲ្យបានយ៉ាងតិចណាស់ម្នាក់អំពីការយាងមកវិញឆាប់ៗរបស់ព្រះយេស៊ូវ និង របៀបត្រៀមខ្លួនទទួលព្រះអង្គ។

(ខព្រះគម្ពីរសិក្សាបន្ថែមស្តីអំពីការយាងវិលត្រលប់មកវិញរបស់ព្រះយេស៊ូវគ្រិស្តៈ
ថែស្សាឡូនីចទី១ ៥:២៣-២៤ និងយ៉ូហានទី៣ ខ ២-៣)

# ការជឿទុកចិត្តលើព្រះបន្ទូលនៃព្រះ

## ពួកសាវ័កនាសម័យចុងក្រោយ មេរៀន ទី១០



### សរសើរតម្កើងព្រះ និងអធិស្ឋាន

- តើលោកអ្នកមានអ្វីសរសើរតម្កើងព្រះទេ បន្ទាប់ពីយើងជួបគ្នាកន្លងមកនេះ?
- ថ្មីៗនេះតើមានអ្វីខ្លះដែលលោកអ្នកកំពុងព្រួយបារម្ភដែរទេ?
- សូមអធិស្ឋានសំរាប់សេចក្តីត្រូវការឲ្យគ្នាទៅវិញទៅមក។ ចូរសូមព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណបរិសុទ្ធស្ថិតក្នុងការជួបប្រជុំគ្នានេះ។

### ការរំឭកឡើងវិញ

- ចូរសូត្រខចងចាំជាមួយដៃគូម្នាក់ ឬពីរនាក់។
- តើលោកអ្នកបានរៀនអ្វីខ្លះកាលពីលើកមុន?
- តើមានការប្រែប្រួលអ្វីខ្លះក្នុងជីវិតរបស់អ្នក ដោយព្រោះសេចក្តីពិតដែលអ្នកបានរៀនពីមេរៀនមុននោះ?
- តើលោកអ្នកបានចែករំលែកអ្វីដែលបានរៀនកន្លងមកទៅកាន់នរណាខ្លះ?

### ការសិក្សាព្រះបន្ទូល

១) សូមអានព្រះគម្ពីរ ដានីយ៉ែល ២:១-១៣។ តើស្តេចនេប៊ូក្នេសាបង្គាប់អោយពួកអ្នកប្រាជ្ញរបស់ទ្រង់ធ្វើអ្វីសំរាប់ទ្រង់?

២) សូមអានព្រះគម្ពីរ ដានីយ៉ែល ២:១៤-១៨។ តើលោកដានីយ៉ែលបានធ្វើអ្វី នៅគ្រាដែលជីវិតគាត់កំពុងតែ ស្ថិតក្នុងគ្រោះថ្នាក់ដូចអ្នកប្រាជ្ញដទៃទៀត?

៣) សូមអានព្រះគម្ពីរ ដានីយ៉ែល ២:១៩-៣០។ តើលោកដានីយ៉ែលមានការឆ្លើយតបយ៉ាងណា បន្ទាប់ពីព្រះ បានបើកបង្ហាញអោយយល់ ពីសេចក្តីអាថ៌កំបាំងនៃសុបិនរបស់ស្តេចនេប៊ូក្នេសា?

៤) សូមអានព្រះគម្ពីរ ដានីយ៉ែល ២:៣១-៤៥។ តើស្តេចនេប៊ូក្នេសាបានសុបិនឃើញអ្វី?

៥) សូមអានព្រះគម្ពីរ ដានីយ៉ែល ២:៣៨-៤០។ តើលោហៈទាំងបួនប្រភេទនៃរូបសំណាក់នោះដំណាងអោយ អ្វីខ្លះ ?

៦) តាមរយៈសុបិននិមិត្ត លោកដានីយ៉ែលបានពន្យល់បង្ហាញពីអាណាចក្រដ៏មានឥទ្ធិពលទាំងបួននៅលើផែនដីយើងនេះ។ ជាងរយៈពេល២០០០ឆ្នាំ ប្រវត្តិសាស្រ្តបានកំណត់ត្រាទុកអំពីអាណាចក្រទាំងបួនដែលព្រះបានបង្ហាញយ៉ាងពិតប្រាកដមែន រួមមាន អាណាចក្របាប៊ីឡូន មេឌូពើស៊ី ក្រិក និង រ៉ូម។ សូមអានព្រះគម្ពីរ ធីម៉ូថេទី១ ៦:៦-៨, ១៧-១៩។ គ្រប់ទាំងអ្វីៗនៅលើផែនដីនេះនឹងត្រូវបានបំផ្លាញ ដូច្នេះតើអ្នកគួរមានគំនិតយ៉ាងណាចំពោះលុយកាក់ ទ្រព្យសម្បត្តិ និងដំណែងផ្សេងៗទៀត ?

៧) សូមអានព្រះគម្ពីរ ដានីយ៉ែល ២:៤១-៤៣។ តើព្រះទ្រង់មានបន្ទូលប្រាប់យើងរាល់គ្នាថានឹងមានអ្វីកើតឡើងខ្លះ បន្ទាប់ពីអាណាចក្រទាំងបួនត្រូវបានរលាយបាត់ទៅ?

៨) គ្មានមេដឹកនាំកំពូលណាអាចនឹងបង្រួបបង្រួមទឹកដីអឺរ៉ុប និងមជ្ឈិមបូព៌ាបាននោះទេ បន្ទាប់ពីអាណាចក្រទីបួនដែលជាអាណាចក្ររ៉ូមបានរលាយបាត់ ទោះបីជាស្តេចឆាឡេម៉េ ណាប៉ូឡេអុង ឬអ៊ីត្លែក៏ដោយ។ យើងទាំងអស់គ្នាកំពុងរស់នៅគ្រាចុងក្រោយបង្អស់ ដែលជាប្រអប់ជើងរបស់រូបសំណាក។ សូមអានម្តងទៀតនៅព្រះគម្ពីរ ដានីយ៉ែល ២:៣៤-៣៥ និង៤៤។ តើមានព្រឹត្តិការណ៍អស្ចារ្យអ្វីដែលនឹងកើតមានឡើងបន្តទៅទៀតនេះ?

៩) ការដែលសិក្សាលើបទទំនាយ អាចជួយអោយយើងយល់កាន់តែច្បាស់ថា យើងពិតជាអាចជឿទុកចិត្តលើព្រះគម្ពីរបានយ៉ាងប្រាកដមែន។ សូមអានព្រះគម្ពីរ ធីម៉ូថេទី២ ៣:១៥-១៧។ តើការអានព្រះគម្ពីរអាចជួយ យើងបានយ៉ាងដូចម្តេចខ្លះនាគ្រាចុងក្រោយបង្អស់នេះ?

១០) សូមរកពេលវេលាស្ងប់ស្ងាត់មួយ ដើម្បីសញ្ជឹងគិតឡើងវិញនូវអ្វីដែលអ្នកបានរៀនមុននេះ។ ចូរទូលសូម ដល់ព្រះអម្ចាស់យេស៊ូវគ្រិស្តអោយទ្រង់បានបំផ្លាស់បំប្រែនូវបញ្ហាដែលកើតមានឡើងនៅក្នុងចិត្ត និងជីវិតរបស់អ្នក ប្រយោជន៍អោយអ្នកបានត្រៀមខ្លួនរួចជាស្រេច ក្នុងការរង់ចាំនូវការយាងវិលត្រលប់មកវិញរបស់ទ្រង់។

## ចែកចាយ និងអធិស្ឋាន

□ នៅថ្ងៃនេះ តើលោកអ្នកបានរៀនអ្វីខ្លះដែលលោកអ្នកអាចនឹងយកទៅអនុវត្តនៅសប្តាហ៍នេះ ដោយពឹងលើអំណាចរបស់ព្រះជាម្ចាស់?

□ ចូរពិភាក្សាអំពីសេចក្តីត្រូវការក្នុងគ្រួសារ និងសហគមន៍ព្រមទាំងការប្តេជ្ញាចិត្តរបស់លោកអ្នក ហើយសំរេចចិត្តថា តើមានអ្វីខ្លះដែលលោកអ្នកអាចជួយបាន?

□ សូមអធិស្ឋានឲ្យគ្នាទៅវិញទៅមក សំរាប់គ្រួសារនិងសហគមន៍របស់លោកអ្នកនៅពេលឥឡូវនេះ។

## កិច្ចការពិសេស ឬកិច្ចអនុវត្តន៍

□ សូមទន្ទេញខព្រះគម្ពីរ អេសាយ ៤០:៨។

□ សូមចែកចាយនូវអ្វីដែលអ្នកបានដឹងអំពីការយាងមកដ៏ឆាប់ៗរបស់ព្រះយេស៊ូវគ្រិស្តនិងរបៀបរៀបចំខ្លួន ថ្វាយទ្រង់ដល់មនុស្សម្នាក់យ៉ាងតិច។

(ខព្រះគម្ពីរសិក្សាបន្ថែមស្តីអំពីការយាងវិលត្រលប់មកវិញរបស់ព្រះយេស៊ូវគ្រិស្ត៖ លូកា១៧:២៨-៣៣ និង ពេត្រុសទី១ ១:១៣-២៥)

# ចូរស្មោះត្រង់លុះក្ស័យ

## ពួកសាវ័កនាសម័យចុងក្រោយ មេរៀន ទី១១



### សរសើរតម្កើងព្រះ និងអធិស្ឋាន

- តើលោកអ្នកមានអ្វីសរសើរតម្កើងព្រះទេ បន្ទាប់ពីយើងជួបគ្នាកន្លងមកនេះ?
- ថ្មីៗនេះតើមានអ្វីខ្លះដែលលោកអ្នកកំពុងព្រួយបារម្ភដែរទេ?
- សូមអធិស្ឋានសំរាប់សេចក្តីត្រូវការឲ្យគ្នាទៅវិញទៅមក។ ចូរសូមព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណបរិសុទ្ធស្ថិតក្នុងការជួបប្រជុំគ្នានេះ។

### ការរំឮកឡើងវិញ

- ចូរសូត្រខចងចាំជាមួយដៃគូម្នាក់ ឬពីរនាក់។
- តើលោកអ្នកបានរៀនអ្វីខ្លះកាលពីលើកមុន?
- តើមានការប្រែប្រួលអ្វីខ្លះក្នុងជីវិតរបស់អ្នក ដោយព្រោះសេចក្តីពិតដែលអ្នកបានរៀនពីមេរៀនមុននោះ?
- តើលោកអ្នកបានចែករំលែកអ្វីដែលបានរៀនកន្លងមកទៅកាន់នរណាខ្លះ?

### ការសិក្សាព្រះបន្ទូល

១) សូមអានព្រះគម្ពីរ ដានីយ៉ែល ៣:១-៧។ តាមរយៈសុបិននិមិត្តនៅក្នុងព្រះគម្ពីរដានីយ៉ែលជំពូក២ ព្រះជាម្ចាស់បានបង្ហាញអោយស្តេចនេប៊ូក្នេសាឃើញថា ព្រះអង្គគឺជាព្រះនៃលើអស់ទាំងស្តេច ហើយអាណាចក្របាប៊ីឡូន នឹងមិនស្ថិតស្ថេរជាដរាបនោះទេ។ ក៏បង្ហាញផងដែរថា អាណាចក្របាប៊ីឡូនគឺគ្រាន់តែជាក្បាល ធ្វើអំពីមាស ហើយនឹងត្រូវរលាយបាត់ទៅក្រោមឥទ្ធិពលនៃអាណាចក្រមួយផ្សេងទៀតដែលជំណាងដោយប្រាក់វិញតែប៉ុណ្ណោះ។ ផ្ទុយពីការគោរពកោតខ្លាចដល់ព្រះជាម្ចាស់ តើស្តេចនេប៊ូក្នេសាបានបញ្ជាអោយគេសាងសង់អ្វី? ហើយទ្រង់រំពឹងអោយប្រជានុរាស្ត្រធ្វើអ្វីចំពោះសំណង់មួយនោះ?

២) សូមអានព្រះគម្ពីរ ដានីយ៉ែល ៣:៨-១៨។ នៅពេលដែលស្តេចនេប៊ូក្នេសាបង្គាប់គំរាមដល់អ្នកគោរពប្រតិបត្តិព្រះទាំងបីនាក់ នោះតើពួកគេមានការឆ្លើយតបយ៉ាងដូចម្តេចខ្លះមកកាន់ទ្រង់វិញ ?

៣) សូមអានព្រះគម្ពីរ ដានីយ៉ែល ៣:១៩-៣០។ តើព្រះជាម្ចាស់បានធ្វើអ្វីខ្លះចំពោះបុរសទាំងបីនាក់ដែលមានភាពស្មោះត្រង់ និងជឿទុកចិត្តលើទ្រង់?

៤) សូមអានព្រះគម្ពីរ និក្ខមនំ ២០:៣-៦។ តើព្រះជាម្ចាស់បានបង្គាប់យើងយ៉ាងដូចម្ដេចខ្លះអំពីការថ្វាយបង្គំរូបសំណាក ឬរូបព្រះ ?

៥) សូមអានព្រះគម្ពីរ អេសាយ ៤៤:៦, ៩-១០។ ហេតុអ្វីបានជាយើងត្រូវថ្វាយបង្គំព្រះដ៏ជាអម្ចាស់នៃយើងតែមួយអង្គយ៉ាងដូច្នេះ ?

៦) ក្រៅពីការថ្វាយបង្គំរូបព្រះដែលធ្វើពីឈើ ឬលោហៈ តើនៅមានអ្វីផ្សេងទៀតដែលមនុស្សថ្វាយបង្គំ ឬក៏ស្រលាញ់ជាជាងព្រះជាម្ចាស់?

៧) សូមអានព្រះគម្ពីរ ម៉ាថាយ ១០:២៧-៣៣។ តើខព្រះគម្ពីរទាំងនេះអាចជួយអ្វីខ្លះដល់អ្នកដើម្បីឈរតតាំងដោយក្លាហានប្រឆាំងនឹងការថ្វាយបង្គំរូបព្រះ និងសម្ពាធមិត្តភ័ក្ររបស់អ្នក?

៨) សូមអានព្រះគម្ពីរ កូរិនថូសទី២ ៦:១៦-១៨ និង ៧:១។ តើយើងត្រូវធ្វើដូចម្ដេចដើម្បីមានអំណាចគ្រប់គ្រងលើជីវិតដែលនឹងត្រូវថ្វាយដល់ព្រះ?

៩) សូមរកពេលវេលាស្ងប់ស្ងាត់មួយ ដើម្បីសញ្ជឹងគិតឡើងវិញនូវអ្វីដែលអ្នកបានរៀនមុននេះ។ ចូរទូលសូម ដល់ព្រះអម្ចាស់យេស៊ូវគ្រិស្ដអោយទ្រង់បានបំផ្លាស់បំប្រែនូវបញ្ហាដែលកើតមានឡើងនៅក្នុងចិត្ត និងជីវិតរបស់អ្នក ប្រយោជន៍អោយអ្នកបានត្រៀមខ្លួនរួចជាស្រេច ក្នុងការរង់ចាំនូវការយាងវិលត្រលប់មកវិញរបស់ទ្រង់។

## ចែកចាយ និងអធិស្ឋាន

- នៅថ្ងៃនេះ តើលោកអ្នកបានរៀនអ្វីខ្លះដែលលោកអ្នកអាចនឹងយកទៅអនុវត្តនៅសប្ដាហ៍នេះដោយពឹងលើអំណាចរបស់ព្រះជាម្ចាស់?

- ចូរពិភាក្សាអំពីសេចក្ដីត្រូវការក្នុងគ្រួសារ និងសហគមន៍ព្រមទាំងការប្ដេជ្ញាចិត្តរបស់លោកអ្នក ហើយសំរេចចិត្តថា តើមានអ្វីខ្លះដែលលោកអ្នកអាចជួយបាន?

- សូមអធិស្ឋានឲ្យគ្នាទៅវិញទៅមក សំរាប់គ្រួសារនិងសហគមន៍របស់លោកអ្នកនៅពេលឥឡូវនេះ។

## កិច្ចការពិសេស ឬកិច្ចអនុវត្តន៍

- សូមទន្ទេញខព្រះគម្ពីរ និក្ខមនំ ២០:៣។
- សូមចែកចាយនូវអ្វីដែលអ្នកបានដឹងអំពីការយាងមកដ៏ឆាប់ៗរបស់ព្រះយេស៊ូវគ្រិស្ដនិងរៀបចំខ្លួនថ្វាយទ្រង់ដល់មនុស្សម្នាក់យ៉ាងតិច។
  (ខព្រះគម្ពីរសិក្សាបន្ថែមស្ដីអំពីការយាងវិលត្រលប់មកវិញរបស់ព្រះយេស៊ូវគ្រិស្ដ៖ ពេត្រុសទី២ ១:១-១១ និង ពេត្រុសទី១ ៤:១២-១៩)

# ចូរបន្ទាបចិត្តរបស់អ្នក

## ពួកសាវ័កនាសម័យចុងក្រោយ មេរៀន ទី១២



## សរសើរតម្កើងព្រះ និងអធិស្ឋាន

- តើលោកអ្នកមានអ្វីសរសើរតម្កើងព្រះទេ បន្ទាប់ពីយើងជួបគ្នាកន្លងមកនេះ?
- ថ្មីៗនេះតើមានអ្វីខ្លះដែលលោកអ្នកកំពុងព្រួយបារម្ភដែរទេ?
- សូមអធិស្ឋានសំរាប់សេចក្តីត្រូវការឲ្យគ្នាទៅវិញទៅមក។ ចូរសូមព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណបរិសុទ្ធស្ថិតក្នុងការជួបប្រជុំគ្នានេះ។

## ការរំឭកឡើងវិញ

- ចូរសូត្រខចងចាំជាមួយដៃគូម្នាក់ ឬពីរនាក់។
- តើលោកអ្នកបានរៀនអ្វីខ្លះកាលពីលើកមុន?
- តើមានការប្រែប្រួលអ្វីខ្លះក្នុងជីវិតរបស់អ្នក ដោយព្រោះសេចក្តីពិតដែលអ្នកបានរៀនពីមេរៀនមុននោះ?
- តើលោកអ្នកបានចែករំលែកអ្វីដែលបានរៀនកន្លងមកទៅកាន់នរណាខ្លះ?

## ការសិក្សាព្រះបន្ទូល

១) សូមអានព្រះគម្ពីរ ដានីយ៉ែល ៤:៤-១៧។ តើស្តេចនេប៊ូក្នេសាបានសុបិនឃើញអ្វី?
២) សូមអានព្រះគម្ពីរ ដានីយ៉ែល ៤:១៨-២៦។ តើសុបិននោះមានអត្ថន័យយ៉ាងដូចម្តេច ?
៣) សូមអានព្រះគម្ពីរ ដានីយ៉ែល ៤:២៧។ តើលោកដានីយ៉ែលបានផ្តល់សេចក្តីទូន្មានយ៉ាងដូចម្តេចខ្លះទៅកាន់ស្តេចនេប៊ូក្នេសា ?
៤) សូមអានព្រះគម្ពីរ ដានីយ៉ែល ៤:២៨-៣៧។ ទីបំផុត តើមេរៀនអ្វីដែលស្តេចនេប៊ូក្នេសាបានរៀនពីព្រះ ?
៥) តើអ្នកធ្លាប់ឃើញសេចក្តីអំនួតបង្កបញ្ហាដល់មនុស្សដែរឬទេ? ដោយរបៀបណា ?
៦) សូមអានព្រះគម្ពីរ របាក្សត្រទី១ ២៩:១០-១៤។ តើស្តេចដាវីឌ ដែលជាមេដឹកនាំមួយរូបផ្សេងទៀត បានបង្ហាញអោយយើងឃើញយ៉ាងដូចម្តេចខ្លះពីភាពជោគជ័យ និងអ្វីៗដែលទ្រង់មាន ?
៧) ស្តេចនេប៊ូក្នេសានឹងមិនមានការប្រែចិត្តពិត ហើយទទួលបានសេចក្តីសង្គ្រោះឡើយ ទាល់តែទ្រង់បានជួបនូវភាពអស្ចារ្យធំៗចំនួនបួនដងនៅក្នុងជីវិតទ្រង់ ដែលលើកឡើងមកបរិយាយនៅក្នុងព្រះគម្ពីរ

ដានីយ៉ែលរហូតដល់ចំនួនបួនជំពូក។ សូមអានព្រះគម្ពីរ កូរិនថូសទី២ ៧:៩-១១។ តើការប្រែចិត្តពិតមានលក្ខណៈដូចម្តេចខ្លះ?

៨) ពេលខ្លះយើងមិនមានការសោកស្តាយពីបាបដែលយើងមាននោះទេ។ សូមអានព្រះគម្ពីរ កិច្ចការ ៥:៣១។ តើនរណាអាចជួយអោយយើងមានសមត្ថភាពប្រែចិត្តបាន?

៩) សូមអានព្រះគម្ពីរ យ៉ាកុប ៤:៦-១០។ ហេតុអ្វីបានជាការបន្ទាបខ្លួនមានសារៈសំខាន់ខ្លាំងម្លេះ ដើម្បីឈានដល់ការទទួលបាននូវសេចក្តីសង្គ្រោះ និងជ័យជំនះ?

១០) សូមអានព្រះគម្ពីរ អេភេសូរ ២:៤-១០។ មានតែព្រះយេស៊ូវប៉ុណ្ណោះដែលអាចរៀបចំចិត្តអ្នកសំរាប់ការយាងមកវិញរបស់ទ្រង់ក្នុងពេលដ៏ឆាប់នេះ។ តើអ្នកមានទំនុកចិត្តលើខ្លួនឯងដែរឬទេថា អ្នកពិតជាបានទទួលនូវសេចក្តីសង្គ្រោះពីព្រះ?

១១) សូមរកពេលវេលាស្ងប់ស្ងាត់មួយ ដើម្បីសញ្ជឹងគិតឡើងវិញនូវអ្វីដែលអ្នកបានរៀនមុននេះ។ ចូរទូលសូម ដល់ព្រះអម្ចាស់យេស៊ូវគ្រិស្តអោយទ្រង់បានបំផ្លាស់បំប្រែនូវបញ្ហាដែលកើតមានឡើងនៅក្នុងចិត្ត និងជីវិតរបស់អ្នក ប្រយោជន៍អោយអ្នកបានត្រៀមខ្លួនរួចជាស្រេច ក្នុងការរង់ចាំនូវការយាងវិលត្រលប់មកវិញរបស់ទ្រង់។

## ចែកចាយ និងអធិស្ឋាន

- □ នៅថ្ងៃនេះ តើលោកអ្នកបានរៀនអ្វីខ្លះដែលលោកអ្នកអាចនឹងយកទៅអនុវត្តនៅសប្តាហ៍នេះ ដោយពឹងលើអំណាចរបស់ព្រះជាម្ចាស់?
- □ ចូរពិភាក្សាអំពីសេចក្តីត្រូវការក្នុងគ្រួសារ និងសហគមន៍ព្រមទាំងការប្តេជ្ញាចិត្តរបស់លោកអ្នក ហើយសំរេចចិត្តថា តើមានអ្វីខ្លះដែលលោកអ្នកអាចជួយបាន?
- □ សូមអធិស្ឋានឲ្យគ្នាទៅវិញទៅមក សំរាប់គ្រួសារនិងសហគមន៍របស់លោកអ្នកនៅពេលឥឡូវនេះ។

## កិច្ចការពិសេស ឬកិច្ចអនុវត្តន៍

- □ សូមទន្ទេញខព្រះគម្ពីរ យ៉ាកុប ៤:១០។
- □ សូមចែកចាយនូវអ្វីដែលអ្នកបានដឹងអំពីការយាងមកដ៏ឆាប់ៗរបស់ព្រះយេស៊ូវគ្រិស្តនិងរបៀបរៀបចំខ្លួន ថ្វាយទ្រង់ដល់មនុស្សម្នាក់យ៉ាងតិច។
(ខព្រះគម្ពីរសិក្សាបន្ថែមស្តីអំពីការយាងវិលត្រលប់មកវិញរបស់ព្រះយេស៊ូវគ្រិស្តៈ ពេត្រុសទី១ ៤:១-៨ និង លូកា ១៨:៩-១៤)

# ទុកចិត្តលើការការពាររបស់ព្រះ

## ពួកសាវ័កនាសម័យចុងក្រោយ មេរៀន ទី១៣



## សរសើរតម្កើងព្រះ និងអធិស្ឋាន

- តាំងពីយើងបានជួបគ្នាលើកមុនរហូតមកទល់ពេលនេះ តើមានរឿងអ្វីខ្លះដែលអ្នកចង់សរសើរតម្កើងព្រះ?
- តើមួយរយៈថ្មីនេះអ្នកមានក្តីបារម្ភអ្វីខ្លះ?
- សូមអធិស្ឋានសំរាប់សេចក្តីត្រូវការឲ្យគ្នាទៅវិញទៅមក។ ចូរទូលសូមព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណបរិសុទ្ធគង់ជាមួយក្នុងការជួបប្រជុំគ្នានេះ។

## ការរំឭកឡើងវិញ

- ចូរសូត្រខចងចាំកាលពីលើកមុនឡើងវិញជាមួយដៃគូម្នាក់ ឬពីរនាក់ផ្សេងទៀត។
- តើលោកអ្នកបានរៀនអ្វីខ្លះកាលពីលើកមុន?
- តើមានការប្រែប្រួលអ្វីខ្លះក្នុងជីវិតរបស់អ្នក ដោយព្រោះសេចក្តីពិតដែលអ្នកបានរៀនពីមេរៀនមុននោះ?
- តើលោកអ្នកបានចែករំលែកអ្វីដែលបានរៀនកន្លងមកទៅកាន់នរណាខ្លះ?

## ការសិក្សាព្រះបន្ទូល

១ អានគម្ពីរដានីយ៉ែល ៥៖៣១ និង ៦៖១-៤។ នៅពេលដែលនគរមេដូពើស៊ីថ្មីកើតឡើង ហេតុដូចម្តេចបានជាស្តេចដារីយូសរើសឲ្យដានីយ៉ែលជួយគ្រប់គ្រងព្រះអង្គ?

២ អានគម្ពីរដានីយ៉ែល ៦៖៥-៩។ តើអ្នកដឹកនាំដទៃទៀតជម្រុញឲ្យស្តេចចេញច្បាប់អ្វីដើម្បីពួកគេអាចកម្ចាត់ដានីយ៉ែលបាន?

៣ អានគម្ពីរដានីយ៉ែល ៦៖១០។ តើដានីយ៉ែលបង្ហាញពីសេចក្តីក្លាហាននិងចិត្តស្មោះស្ម័គ្រចំពោះព្រះជាម្ចាស់តាមវិធីណា?

៤ អានគម្ពីរដានីយ៉ែល ៦៖១១-១៧។ តើមានរឿងអ្វីកើតឡើងចំពោះដានីយ៉ែលដោយព្រោះសេចក្តីស្មោះត្រង់របស់គាត់?

៥ អានគម្ពីរដានីយ៉ែល ៦៖១៨-២៣។ តើព្រះបានធ្វើអ្វីដើម្បីសង្គ្រោះដានីយ៉ែល?

៦ អានគម្ពីរដានីយ៉ែល ៦៖២៤-២៨។ តើព្រះរាជាតបយ៉ាងដូចម្តេច?

៧ តើមនុស្សយើងទុកចិត្តទៅលើអ្វីខ្លះឲ្យការពារខ្លួន?

៨ អានគម្ពីរហេព្រើរ ១៣៖៥-៦។ មានមនុស្សជាច្រើនចំណាយថវិកាជាច្រើនលើសលប់ដើម្បីបានវត្ថុស័ក្តិសិទ្ធិ សាក់ បុណ្យទានផ្សេងៗ សក់កណ្តាញ់ កាំភ្លើង និងរបស់ដទៃទៀតដែលពួកគេយល់ថានឹងអាចជួយការពារពួកគេបាន។ ចុះតើគ្រីស្ទានគួរទុកចិត្តទៅលើអ្វីវិញ?

៩ អានគម្ពីរទំនុកដំកើង ៩១៖៩-១៦។ នៅគ្រាចុងក្រោយបង្អស់ ផែនដីរបស់យើងនឹងសម្បូរទៅដោយគ្រោះថ្នាក់និងព្រឹត្តិការណ៍រន្ធត់ៗជាច្រើន។ រឿងដែលសំខាន់មួយគឺយើងត្រូវចង់ចាំថាព្រះបានជួយយើងអ្វីខ្លះកាលពីដើម និងចាំសេចក្តីសន្យារបស់ព្រះអង្គដូចជានៅក្នុងគម្ពីរទំនុកដំកើងជំពូក៩១ជាដើម។ តើព្រះហើយនិងទេវតារបស់ទ្រង់ការពារអ្នកមែនទេ?

១០ អានគម្ពីរយ៉ាកុប ១៖២-៤។ ប្រសិនបើអ្នកទុកចិត្តលើព្រះ តើជីវិតរបស់អ្នកនឹងជៀសផុតពីទុក្ខលំបាករហូតឬ?

១១ ចំណាយពេលខ្លីមួយដើម្បីគិតអំពីមេរៀនដែលអ្នកទើបតែបានសិក្សារួចមក។ ចូរទូលសុំទៅព្រះឲ្យបង្ហាញអ្នកថាតើនៅមានរឿងណាខ្លះទៀតដែលត្រូវផ្លាស់ប្តូរនៅក្នុងចិត្តអ្នកដើម្បីត្រៀមខ្លួនឲ្យរួចរាល់សម្រាប់ការយាងមករបស់ព្រះយេស៊ូវ។

## ចែកចាយ និងអធិស្ឋាន

□ នៅថ្ងៃនេះ តើលោកអ្នកបានរៀនអ្វីខ្លះដែលលោកអ្នកអាចនឹងយកទៅអនុវត្តនៅសប្តាហ៍នេះ ដោយពឹងលើអំណាចរបស់ព្រះជាម្ចាស់?

□ ចូរពិភាក្សាអំពីសេចក្តីត្រូវការក្នុងគ្រួសារ និងសហគមន៍ព្រមទាំងការប្តេជ្ញាចិត្តរបស់លោកអ្នក ហើយសំរេចចិត្តថា តើមានអ្វីខ្លះដែលលោកអ្នកអាចជួយបាន?

□ សូមអធិស្ឋានឲ្យគ្នាទៅវិញទៅមក សំរាប់គ្រួសារនិងសហគមន៍របស់លោកអ្នកនៅពេលឥឡូវនេះ។

## កិច្ចការពិសេស ឬកិច្ចអនុវត្តន៍

□ សម្រាប់សប្តាហ៍នេះសូមទន្ទេញគម្ពីរហេព្រើរ ១៣៖៦។

□ ចូរចែកចាយការអ្វីដែលអ្នកយល់ដឹងអំពីការយាងមកឆាប់ៗរបស់ព្រះយេស៊ូវនិងពីរបៀបដែលត្រូវត្រៀមខ្លួនឲ្យរួចរាល់យ៉ាងហោចណាស់ឲ្យបានទៅកាន់មនុស្សម្នាក់។

(អត្ថបទដទៃទៀតនៃការយាងមករបស់ព្រះយេស៊ូវសម្រាប់រៀនសូត្របន្ថែម៖ ពេត្រុសទី១ ១៖៣-៩)។

# ត្រៀមខ្លួនសម្រាប់ការជំនុំជម្រះរបស់ព្រះ

## ពួកសាវ័កនាសម័យចុងក្រោយ មេរៀន ទី១៩



## សរសើរតម្កើងព្រះ និងអធិស្ឋាន

- តាំងពីយើងបានជួបគ្នាលើកមុនរហូតមកទល់ពេលនេះ តើមានរឿងអ្វីខ្លះដែលអ្នកចង់សរសើរតម្កើងព្រះ?
- តើមួយរយៈថ្មីនេះអ្នកមានក្តីបារម្ភអ្វីខ្លះ?
- សូមអធិស្ឋានសំរាប់សេចក្តីត្រូវការឲ្យគ្នាទៅវិញទៅមក។ ចូរទូលសូមព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណបរិសុទ្ធគង់ជាមួយក្នុងការជួបប្រជុំគ្នានេះ។

## ការរំឭកឡើងវិញ

- ចូរសូត្រខចងចាំកាលពីលើកមុនឡើងវិញជាមួយដៃគូម្នាក់ ឬពីរនាក់ផ្សេងទៀត។
- តើលោកអ្នកបានរៀនអ្វីខ្លះកាលពីលើកមុន?
- តើមានការប្រែប្រួលអ្វីខ្លះក្នុងជីវិតរបស់អ្នក ដោយព្រោះសេចក្តីពិតដែលអ្នកបានរៀនពីមេរៀនមុននោះ?
- តើលោកអ្នកបានចែករំលែកអ្វីដែលបានរៀនកន្លងមកទៅកាន់នរណាខ្លះ?

## ការសិក្សាព្រះបន្ទូល

១ អានគម្ពីរដានីយ៉ែល ៥៖១-៩។ តើព្រះរាជាបេលសាសារកំពុងធ្វើអ្វីហើយតើព្រះអង្គឃើញអ្វីនៅលើជញ្ជាំង?

២ អានគម្ពីរដានីយ៉ែល ៥៖១០-១២។ ហេតុអ្វីបានជាព្រះមហេសីឲ្យយោបល់ថាពួកគេគួរតែទៅហៅដានីយ៉ែលឲ្យមកបកការសរសេរនៅលើជញ្ជាំង?

៣ អានគម្ពីរដានីយ៉ែល ៥៖១៧-២៨។ តើរឿងដ៏ក្លាហានអ្វីដែលលោកដានីយ៉ែលទូលទៅព្រះរាជាបេលសាសារ?

៤ អានគម្ពីរដានីយ៉ែល ៥៖២៩-៣១។ តើមានរឿងអ្វីចំពោះព្រះរាជាបេលសាសារ?

៥ ព្រះជាម្ចាស់ជំនុំជម្រះស្ដេចបេលសាសារដោយទ្រង់មានសេចក្ដីអំនួត ថ្វាយបង្គំបដិមា ព្រមទាំងការបដិសេធនិងប្រមាថព្រះ។ ព្រះដែលនៅក្នុងគម្ពីរគឺជាចៅក្រមដែលល្អជាងគេបំផុត។ អានគម្ពីរដានីយ៉ែល ៧៖៩-១០។ តើបល្ល័ង្កកាត់ក្ដីរបស់ព្រះមានលក្ខណៈបែបណា?

៦ សៀវភៅក៏បើកឡើងនៅឯបល្ល័ង្កជំនុំជម្រះរបស់ព្រះ។ អានគម្ពីរសាស្ដា ១២៖១៣-១៤។ តើព្រះនឹងជំនុំជម្រះមនុស្សពីអ្វី?

៧ ដោយព្រោះយើងមានបាប នោះយើងនឹងជាប់ទោសនៅគ្រាជំនុំជម្រះ។ អានគម្ពីរ យ៉ូហានទី១ ១៖៩-១០ ២៖១-២។ តើយើងត្រូវធ្វើអ្វីទើបព្រះអាចប្រកាសថាយើងបានស្អាតហើយៗទទួលបានការអភ័យទោស?

៨ អានគម្ពីរហេព្រើរ ១០៖៣០-៣១ ៣៥-៣៩។ ដោយព្រោះថាការជំនុំជម្រះរបស់ព្រះពិតជានឹងកើតមានមែន តើយើងគួរធ្វើអ្វី?

៩ ចំណាយពេលស្ងៀមស្ងាត់បន្តិចដើម្បីសញ្ជឹងគិតពីមេរៀនដែលអ្នកបានរៀន។ ចូរទូលសុំទៅព្រះឲ្យបង្ហាញអ្នកថាតើនៅមានរឿងណាខ្លះទៀតដែលត្រូវផ្លាស់ប្ដូរនៅក្នុងចិត្តអ្នកដើម្បីត្រៀមខ្លួនឲ្យរួចរាល់សម្រាប់ការយាងមករបស់ព្រះយេស៊ូវ។

## ចែកចាយ និងអធិស្ឋាន

□ នៅថ្ងៃនេះ តើលោកអ្នកបានរៀនអ្វីខ្លះដែលលោកអ្នកអាចនឹងយកទៅអនុវត្តនៅសប្ដាហ៍នេះដោយពឹងលើអំណាចរបស់ព្រះជាម្ចាស់?

□ ចូរពិភាក្សាអំពីសេចក្ដីត្រូវការក្នុងគ្រួសារ និងសហគមន៍ព្រមទាំងការប្ដេជ្ញាចិត្តរបស់លោកអ្នក ហើយសំរេចចិត្តថា តើមានអ្វីខ្លះដែលលោកអ្នកអាចជួយបាន?

□ សូមអធិស្ឋានឲ្យគ្នាទៅវិញទៅមក សំរាប់គ្រួសារនិងសហគមន៍របស់លោកអ្នកនៅពេលឥឡូវនេះ។

## កិច្ចការពិសេស ឬកិច្ចអនុវត្តន៍

□ ទន្ទេញគម្ពីរយ៉ូហានទី១ ២៖១។

□ ចូរចែកចាយអីការដែលអ្នកយល់ដឹងអំពីការយាងមកឆាប់ៗរបស់ព្រះយេស៊ូវនិងពីរបៀបដែលត្រូវត្រៀមខ្លួនឲ្យរួចរាល់យ៉ាងហោចណាស់ឲ្យបានទៅកាន់មនុស្សម្នាក់។

(មេរៀនបន្ថែមសម្រាប់សិក្សាពីការយាងមករបស់ព្រះយេស៊ូវ៖ មាឡាគី៣៖១៦-១៨និក្ខមនំ ៣២៖៣២-៣៣ វិវរណៈ ៣៖៥ កូរិនថូសទី១ ១១៖៣១-៣២)។

# ទុកចិត្តតែលើអង្គព្រះយេស៊ូវមួយគត់

## ពួកសាវ័កនាសម័យចុងក្រោយ មេរៀន ទី១៥



### សរសើរតម្កើងព្រះ និងអធិស្ឋាន

- តាំងពីយើងបានជួបគ្នាលើកមុនរហូតមកទល់ពេលនេះ តើមានរឿងអ្វីខ្លះដែលអ្នកចង់សរសើរតម្កើងព្រះ?
- តើមួយរយៈថ្មីនេះអ្នកមានក្តីបារម្ភអ្វីខ្លះ?
- សូមអធិស្ឋានសំរាប់សេចក្តីត្រូវការឲ្យគ្នាទៅវិញទៅមក។ ចូរទូលសូមព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណបរិសុទ្ធគង់ជាមួយក្នុងការជួបប្រជុំគ្នានេះ។

### ការរំឭកឡើងវិញ

- ចូរសូត្រខចងចាំកាលពីលើកមុនឡើងវិញជាមួយដៃគូម្នាក់ ឬពីរនាក់ផ្សេងទៀត។
- តើលោកអ្នកបានរៀនអ្វីខ្លះកាលពីលើកមុន?
- តើមានការប្រែប្រួលអ្វីខ្លះក្នុងជីវិតរបស់អ្នក ដោយព្រោះសេចក្តីពិតដែលអ្នកបានរៀនពីមេរៀនមុននោះ?
- តើលោកអ្នកបានចែករំលែកអ្វីដែលបានរៀនកន្លងមកទៅកាន់នរណាខ្លះ?

### ការសិក្សាព្រះបន្ទូល

១ អានគម្ពីរដានីយ៉ែល ៧៖១-៨។ តើលោកដានីយ៉ែលឃើញអ្វីនៅក្នុងការបើកសម្តែងរបស់គាត់?

២ លោកដានីយ៉ែលមិនបានយល់ពីសេចក្តីដែលគាត់បានឃើញទេ។ អានគម្ពីរដានីយ៉ែល ៧៖១៥-១៨។ តើសត្វសាហាវនោះមានអត្ថន័យបែបណាបើយោងទៅតាមទេវតាដែលនិយាយមកកាន់លោកដានីយ៉ែល? (ចំណាំ៖ សត្វនីមួយៗតំណាងឲ្យនគរមួយ ដូចដែលសារធាតុនីមួយៗនៅក្នុងគម្ពីរដានីយ៉ែលជំពូក២ តំណាងឲ្យនគរដូច្នោះដែរ។ សត្វសិង្ហគឺតំណាងឲ្យនគរបាប៊ីឡូន។ សត្វខ្លាឃ្មុំគឺជាអាណាចក្ររួមនៃមេដូហើយនិងពើស៊ី។ សត្វខ្លារខិនគឺតំណាងឲ្យអាណាចក្រក្រិក ដែលបែកជាបួនបន្ទាប់ពីព្រះចៅអធិរាជអាឡេក្សសិនដឺបានសុគតទៅ។ សត្វសាហាវទីបួនគឺជាអាណាចក្ររ៉ូមដែលគ្រប់គ្រងនៅសម័យ ព្រះយេស៊ូវហើយដែលទ្រង់ត្រូវគេឆ្កាងនោះ)។

៣ លោកដានីយ៉ែលចង់យល់អំពីស្នែងតូចដែលចេញពីសត្វទីបួននោះ។ អានគម្ពីរដានីយ៉ែល ៧៖២៤-២៥។ តើស្នែងតូចនោះធ្វើអ្វី?

(ចំណាំ៖ ជាង៤០០ឆ្នាំពួកគ្រីស្ទានប្រូតេស្តង់តែងជឿថាស្នែងតូចនោះគឺជាពួកជំនុំកាតូលិក ដែលកើតចេញពីសាសន៍រ៉ូមនៅពេលដែលពួករ៉ូមឈប់ធ្វើទុក្ខបុកម្នេញពួកគ្រីស្ទានហើយក្លាយមកជាអាណាចក្រមួយប្រកាសថាខ្លួនគឺជាគ្រីស្ទាន។ ពួកជំនុំកាតូលិកកែប្រែសេចក្តីបង្រៀននិងច្បាប់ទម្លាប់មួយចំនួនដែលព្រះយេស៊ូវប្រទានឲ្យទៅពួកជំនុំរបស់ព្រះអង្គ។ ពួកគេអធិដ្ឋានទៅកាន់បុគ្គលបរិសុទ្ធដោយមិនទៅកាន់ព្រះតាមព្រះយេស៊ូវ។ ពួកគេពឹងផ្អែកទៅលើបុណ្យផ្សេងៗជាជាងពឹងលើការសុគតរបស់ព្រះយេស៊ូវតែមួយមុខ។ ពួកគេជឿថាសង្ឃអាចលុបលាងបាបឲ្យគេបានជាជាងព្រះយេស៊ូវតែមួយអង្គ។ ពួកគេផ្លាស់ប្តូរថ្ងៃថ្វាយបង្គំពីថ្ងៃសម្រាករបស់ព្រះយេស៊ូវដែលត្រូវជាថ្ងៃសៅរ៍ទៅថ្ងៃអាទិត្យវិញ។ ហើយពួកគេធ្វើទុក្ខបុកម្នេញនិងសម្លាប់អស់អ្នកដែលមិនយល់ស្របជាមួយពួកគេរាប់សិបឆ្នាំ។

៤ អានគម្ពីរដានីយ៉ែល ៧៖២៤-២៥ សាជាថ្មីហើយប្រៀបធៀបការបរិយាយពីស្នែងតូចទៅនឹងការលើកឡើងខាងលើដែលស្តីអំពីពួកជំនុំកាតូលិក។ តើអ្នកគិតថាការបើកសម្តែងនេះគឺជាការប្រាប់ឲ្យដឹងជាមុនពីប្រភេទគ្រីស្ទានដែលមិនល្អដែរឬទេ?

៥ អានគម្ពីរដានីយ៉ែល ៨៖៩-១២។ ព្រះក៏ប្រទានការបើកសម្តែងមួយទៀតដល់ដានីយ៉ែល ដែលមានស្នែងតូចទៀត។ តើស្នែងតូចវាយប្រហារទៅលើអ្វី?

៦ អានគម្ពីរហេព្រើរ ៨៖១-២។ តើរោងឧបោសថរបស់ព្រះនៅឯណា?

៧ អានគម្ពីរហេព្រើរ ៩៖១១និង១៤។ តើនរណាជាសម្តេចសង្ឃហើយតើដង្វាយយញ្ញបូជារបស់លោកជាអ្វី?
(ចំណាំ៖ មនុស្សជាច្រើនជាថានៅក្នុងគម្ពីរដានីយ៉ែល ៨៖៩-១២ដែលនិយាយពីស្នែងតូចនោះគឺដូចគ្នាទៅនឹងស្នែងតូចនៅក្នុងគម្ពីរដានីយ៉ែលជំពូក៧គឺតំណាងឲ្យពួកជំនុំកាតូលិកដែលវាយប្រហារទៅលើសេចក្តីពិតនៃរោងឧបោសថរបស់ព្រះ ទៅលើសម្តេចសង្ឃ និងដង្វាយយញ្ញបូជា។
ពួកជំនុំនោះបង្វែរមនុស្សឲ្យបែរឆ្ងាយពីការទទួលបានសេចក្តីសង្គ្រោះតាមរយៈព្រះយេស៊ូវពីព្រោះពួកគេផ្តោតទៅលើប្រព័ន្ធថ្វាយយញ្ញបូជា សង្ឃ និងទំនៀមទម្លាប់របស់ពួកគេផ្ទាល់ទៅវិញ)។

៨ អានគម្ពីរថែស្សាឡូនីចទី២ ២៖១-៤។ តើលោកប៉ុលទស្សន៍ទាយថានឹងមានរឿងអ្វីកើតឡើងមុនដែលព្រះយេស៊ូវយាងមកវិញ ហើយតើសេចក្តីនោះស្រដៀងគ្នាទៅនឹងអ្វីដែលយើងបានឃើញពីស្នែងតូចជាយ៉ាងណាដែរ?

៩ អានគម្ពីរថែស្សាឡូនីចទី២ ២៖៨៖១២។ ហេតុដូចម្តេចបានជាគេនឹងបោកមនុស្សលោកអំពីអាទទឹងច្បាប់ ហើយតើធ្វើដូចម្តេចទើបគេមិនអាចបោកបញ្ឆោតយើងបាន?

១០ ចំណាយពេលស្ងៀមស្ងាត់បន្តិចដើម្បីសញ្ជឹងគិតពីមេរៀនដែលអ្នកបានរៀន។ ចូរទូលសុំទៅព្រះឲ្យបង្ហាញអ្នកថាតើនៅមានរឿងណាខ្លះទៀតដែលត្រូវផ្លាស់ប្តូរនៅក្នុងចិត្តអ្នកដើម្បីត្រៀមខ្លួនឲ្យរួចរាល់សម្រាប់ការយាងមករបស់ព្រះយេស៊ូវ។

## ចែកចាយ និងអធិស្ឋាន

☐ នៅថ្ងៃនេះ តើលោកអ្នកបានរៀនអ្វីខ្លះដែលលោកអ្នកអាចនឹងយកទៅអនុវត្តនៅសប្តាហ៍នេះ ដោយពឹងលើអំណាចរបស់ព្រះជាម្ចាស់?

☐ ចូរពិភាក្សាអំពីសេចក្តីត្រូវការក្នុងគ្រួសារ និងសហគមន៍ព្រមទាំងការប្តេជ្ញាចិត្តរបស់លោកអ្នក ហើយសំរេចចិត្តថា តើមានអ្វីខ្លះដែលលោកអ្នកអាចជួយបាន?

☐ សូមអធិស្ឋានឲ្យគ្នាទៅវិញទៅមក សំរាប់គ្រួសារនិងសហគមន៍របស់លោកអ្នកនៅពេលឥឡូវនេះ។

## កិច្ចការពិសេស ឬកិច្ចអនុវត្តន៍

☐ ទន្ទេញគម្ពីរ ហេព្រើរ ១០:២៣ ។

☐ ចូរចែកចាយអីការដែលអ្នកយល់ដឹងអំពីការយាងមកឆាប់ៗរបស់ព្រះយេស៊ូវនិងពីរបៀប ដែលត្រូវត្រៀមខ្លួនឲ្យរួចរាល់យ៉ាងហោចណាស់ឲ្យបានទៅកាន់មនុស្សម្នាក់។

(មេរៀនបន្ថែមសម្រាប់សិក្សាពីការយាងមករបស់ព្រះយេស៊ូវ៖ ហេព្រើរ ៨-១០)។

# ចូរអោយមានទំនុកចិត្តនៅលើព្រះយេស៊ូវ

## ពួកសាវ័កនាសម័យចុងក្រោយ មេរៀន ទី១៦



## សរសើរតម្កើងព្រះ និងអធិស្ឋាន

- តាំងពីយើងបានជួបគ្នាលើកមុនរហូតមកទល់ពេលនេះ តើមានរឿងអ្វីខ្លះដែលអ្នកចង់សរសើរតម្កើងព្រះ?
- តើមួយរយៈថ្មីនេះអ្នកមានក្តីបារម្ភអ្វីខ្លះ?
- សូមអធិស្ឋានសំរាប់សេចក្តីត្រូវការឲ្យគ្នាទៅវិញទៅមក។ ចូរទូលសូមព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណបរិសុទ្ធគង់ជាមួយក្នុងការជួបប្រជុំគ្នានេះ។

## ការរំឭកឡើងវិញ

- ចូរស្សូត្រខចងចាំកាលពីលើកមុនឡើងវិញជាមួយដៃគូម្នាក់ ឬពីរនាក់ផ្សេងទៀត។
- តើលោកអ្នកបានរៀនអ្វីខ្លះកាលពីលើកមុន?
- តើមានការប្រែប្រួលអ្វីខ្លះក្នុងជីវិតរបស់អ្នក ដោយព្រោះសេចក្តីពិតដែលអ្នកបានរៀនពីមេរៀនមុននោះ?
- តើលោកអ្នកបានចែករំលែកអ្វីដែលបានរៀនកន្លងមកទៅកាន់នរណាខ្លះ?

## ការសិក្សាព្រះបន្ទូល

១) ចូរអាចព្រះគម្ពីរ យេរេមា ជំពូក ២៩៖១០-១៤។ តើព្រះទ្រង់បានមានបន្ទូលយ៉ាងដូចម្តេចខ្លះតាមរយៈហោរាយេរេមាទៅកាន់ដានីយ៉ែលនិងអ្នកដទៃទៀតដែលជាឈ្លើយសឹកនៅក្រុងបាប៊ីឡូន?

២) ចូរអានព្រះគម្ពីរ ដានីយ៉ែល ជំពូក ៩៖១៦-១៩។ តើលោកដានីយ៉ែលបានអធិស្ឋានអស់ពីចិត្តទៅលើអ្វី?

៣) ចូរអានព្រះគម្ពីរដានីយ៉ែល ជំពូក ៩៖ ២០-២១។ តើនរណាដែលបានមកឆ្លើយតបចំពោះការអធិស្ឋានរបស់លោកដានីយ៉ែល? តើលោកមកដល់នៅពេលណា?

៤) ចូរអានព្រះគម្ពីរយ៉ូហាន ជំពូក ១៖២៩។ តើកូនចៀមដែលបានបូជា គឺជានិមិត្តសញ្ញាតំណាងអោយអ្នកណា?

៥) ចូរអានព្រះគម្ពីរដានីយ៉ែលជំពូក ៩៖ ២៧-២៩។ ទោះបីជាបានអានខទាំងនេះហើយ វានៅតែពិបាកយល់។ តើលោកអ្នកគិតថាបទទំនាយនេះចង់បង្ហាញអំពីអ្វី រឺ អំពីអ្នកណា?

៦) ចូរអានព្រះគម្ពីរជនគណនា ជំពូក ១៤៖ ៣៣-៣៤ និង អេសេគាល ជំពូក ៤៖៤-៦។ តើមួយថ្ងៃស្មើនិងប៉ុន្មាន? យោងទៅតាមបទទំនាយនេះ?

៧) តើពេលវេលាអ្វីខ្លះ ដែលមានចែងនៅក្នុង ព្រះគម្ពីរដានីយ៉ែល ជំពូក៩៖ ២៤-២៧? តាមរយៈបទទំនាយមួយថ្ងៃតំណាងអោយមួយឆ្នាំ តើពេលវេលាទាំងនោះតំណាងអោយប៉ុន្មានឆ្នាំ?
(ចំណាំ៖ ៧០ សប្តាហ៍ គឺ ៧០x៧ថ្ងៃ=៤៩០ថ្ងៃ, តំណាងអោយ ៤៩០ឆ្នាំ)។
៦២ សប្តាហ៍x៧=៤៨៣ថ្ងៃ, តំណាងអោយ ៤៨៣ឆ្នាំ។ ១ សប្តាហ៍x៧=៧ថ្ងៃ, តំណាងអោយ ៧ឆ្នាំ។)

៨) ចូរអានព្រះគម្ពីរដានីយ៉ែល ជំពូក ៩៖២៥។ តើការចាប់ផ្តើមនៅបទទំនាយនៃពេលវេលានេះគឺជាព្រឹត្តិការណ៍អ្វី?

(ចំណាំ៖ចូរមើលតារាងដើម្បីអោយដឹងពីការបរិច្ឆេទ។ បទទំនាយចាប់ផ្តើមពីដំណាក់ការនៃការសាងសង់ទីក្រុងយេរូសាឡឹមជាថ្មី។ ព្រះគម្ពីរអេសរាបង្ហាញពីបីដំនាក់ការទៅមុខ។ អ្នកប្រវត្តិវិទូទាំងឡាយបានដាក់ពេលវេលានេះគឺ ឆ្នាំ ៤៥៨B.C។ ពួកគេបានរាប់ចាប់ពី៦៩សប្តាហ៍
(៤៨៣ឆ្នាំ) ទៅមុខ ដោយរាប់ចាប់ផ្តើមពីឆ្នាំ 0 រហូតទៅដល់ឆ្នាំ ២៧A.D។ ហើយពួកគេបានរាប់ពីសប្តាហ៍ចុងក្រោយទៅមុខ (៧ឆ្នាំ) រហូតដល់ឆ្នាំ ៣៤A.D។




៩) ចូរអានព្រះគម្ពីរដានីយ៉ែល ជំពូក៩៖២៥។ តើនរណាជាអ្នកដែលត្រូវមកនៅចុងបំផុត៤៨៣ឆ្នាំ?
(ចំណាំ៖អ្នកប្រវត្តិវិទូទាំងឡាយបានបង្ហាញថាព្រះយេស៊ូវចាប់ផ្តើមព័ន្ធកិច្ចរបស់ទ្រង់ចាប់ពីពេលដែលទ្រង់ធ្វើពិធីបុណ្យជ្រមុចទឹកនៅក្នុងរដូវស្លឹកឈើជ្រុះនៃឆ្នាំ ២៧A.D។ ចូរមើលព្រះគម្ពីរ លូកា ជំពូក៣៖១-២ និង៥ ២១-២៣។ ទ្រង់បានត្រូវតែងតាំងអោយក្លាយជាព្រះមែស៊ីដោយព្រះវិញ្ញាណបរិសុទ្ធ។)

១០) ចូរអានព្រះគម្ពីរដានីយ៉ែល ជំពូក៩៖២៦-២៧។ តើមានរឿងអ្វីកើតឡើងដល់ព្រះមែស៊ីនៅក្នុងពាក់កណ្តាលនៃសប្តាហ៍ចុងក្រោយ?
(ចំណាំ៖អ្នកប្រវត្តិវិទូខ្លះបានបង្ហាញថាព្រះយេស៊ូវត្រូវបានសុគតនៅក្នុងនិទាឃរដូវនៃឆ្នាំ ៣១A.D ត្រូវនឹង3-½ ឆ្នាំបន្ទាប់ពីព័ន្ធកិច្ចរបស់ទ្រង់ គឺនៅពាក់កណ្តាលនៃសប្តាហ៍ចុងក្រោយនៃ៧ថ្ងៃ (៧ឆ្នាំ) ។)

១១) ចូរអានព្រះគម្ពីរដានីយ៉ែល ជំពូក៩៖២៧ម្តងទៀត។ តើការខិតខំបកស្រាយអោយដឹងពីពណ៌មានអំពីព្រះយេស៊ូវទាំងអស់នេះ ដែលបានទស្សន៍ទាយទុក្ខ ៤៩០ឆ្នាំ ធ្វើអោយយើងមានអារម្មណ៏យ៉ាងដូចម្តេច?
(ចំណាំ៖៧0សប្តាហ៍ (៤៩0ឆ្នាំ) នឹងបញ្ចប់នៅក្នុងឆ្នាំ ៣៤A.D។ នេះគឺជាពេលដែលស្ទេផានត្រូវបានចោលនឹងដុំថ្មនៅខាងក្រៅទីក្រុងយេរូសាឡឹម គឺ3 ½ ឆ្នាំ បន្ទាប់ពីការសុគតរបស់ព្រះយេស៊ូវ ។ ព្រះគម្ពីរកិច្ចការ ជំពូក៧ និងជំពូក៨ បានពិពណ៌នាអំពីរឿងនេះ ហើយនឹងបង្ហាញថាព្រះយេស៊ូវគង់នៅស្ថានសួគ៌ដែលទ្រង់កំពុងបំពេញព័ន្ធកិច្ចជាសម្តេចសង្ឃជាន់ខ្ពស់ ត្រូវនឹងពេលដែលដំណឹងល្អចាប់ផ្តើមផ្សព្វផ្សាយទៅក្រៅ ទូទាំងពិភពលោក។)

១២) ចូរពិចារណាយ៉ាងស្ងៀមស្ងាត់អំពីអ្វីដែលអ្នកបានរៀន។ ចូរទូលសូមដល់ព្រះ ដើម្បីអោយទ្រង់បំពេញនូវចន្លោះដែលខ្វះខាតនៅក្នុងចិត្ត និងជីវិតរបស់លោកអ្នកប្រសិនបើមាន ដើម្បីត្រៀមលក្ខណៈរួចជាស្រេចសំរាប់ការយាងមករបស់ព្រះយេស៊ូវ។

## ចែកចាយ និងអធិស្ឋាន

□ នៅថ្ងៃនេះ តើលោកអ្នកបានរៀនអ្វីខ្លះដែលលោកអ្នកអាចនឹងយកទៅអនុវត្តនៅសប្តាហ៍នេះដោយពឹងលើអំណាចរបស់ព្រះជាម្ចាស់?

□ ចូរពិភាក្សាអំពីសេចក្តីត្រូវការក្នុងគ្រួសារ និងសហគមន៍ព្រមទាំងការប្តេជ្ញាចិត្តរបស់លោកអ្នកហើយសំរេចចិត្តថា តើមានអ្វីខ្លះដែលលោកអ្នកអាចជួយបាន?

□ សូមអធិស្ឋានឲ្យគ្នាទៅវិញទៅមក សំរាប់គ្រួសារនិងសហគមន៍របស់លោកអ្នកនៅពេលឥឡូវនេះ។

## កិច្ចការពិសេស ឬកិច្ចអនុវត្តន៍

□ ទន្ទេញខព្រះគម្ពីរ ហេព្រើរ ជំពូក ១០៖១២។

□ ចែកចាយជាមួយអ្នកដទៃយ៉ាងហោចណាស់អោយបានម្នាក់ អំពីការជិតយាងមករបស់ព្រះយេស៊ូវ និងកិច្ចការដែលលោកអ្នកត្រូវធ្វើដើម្បីត្រៀមខ្លួនជាស្រេចក្នុងការទទួលទ្រង់។

# ត្រៀមខ្លួនសំរាប់ការលាងសម្អាត

## ពួកសាវ័កនាសម័យចុងក្រោយ មេរៀន ទី១៧



## សរសើរតម្កើងព្រះ និងអធិស្ឋាន

- តាំងពីយើងបានជួបគ្នាលើកមុនរហូតមកទល់ពេលនេះ តើមានរឿងអ្វីខ្លះដែលអ្នកចង់សរសើរតម្កើងព្រះ?
- តើមួយរយៈថ្មីនេះអ្នកមានក្តីបារម្ភអ្វីខ្លះ?
- សូមអធិស្ឋានសំរាប់សេចក្តីត្រូវការឲ្យគ្នាទៅវិញទៅមក។ ចូរទូលសូមព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណបរិសុទ្ធគង់ជាមួយក្នុងការជួបប្រជុំគ្នានេះ។

## ការរំឭកឡើងវិញ

- ចូរសូត្រខចងចាំកាលពីលើកមុនឡើងវិញជាមួយដៃគូម្នាក់ ឬពីរនាក់ផ្សេងទៀត។
- តើលោកអ្នកបានរៀនអ្វីខ្លះកាលពីលើកមុន?
- តើមានការប្រែប្រួលអ្វីខ្លះក្នុងជីវិតរបស់អ្នក ដោយព្រោះសេចក្តីពិតដែលអ្នកបានរៀនពីមេរៀនមុននោះ?
- តើលោកអ្នកបានចែករំលែកអ្វីដែលបានរៀនកន្លងមកទៅកាន់នរណាខ្លះ?

## សិក្សាពីបទបន្ទូលនៃព្រះ

១) ហោរាដានីយ៉ែលមានការព្រួយបារម្ភអំពី ការខូចខាត និងធ្លាក់ចុះនៃរោងឧបោសថរបស់ព្រះនៅលើផែនដី គឺនៅក្នុងក្រុងយេរូសាឡឹម។ ព្រះបានបើកសំដែងដល់គាត់ អំពីរោងឧបោសថដែលសំខាន់បំផុត គឺស្ថិតនៅក្នុងស្ថានសួគ៌។ កាលពីមុន យើងបានរៀនអំពីស្នែងតូចដែលដុះចេញមក គឺតំណាងអោយគ្រីស្ទានក្លែងក្លាយ ពួកគេបានវាយប្រហាររោងឧបោសថរបស់ព្រះ ដោយឃាំងមនុស្សលោកមិនអោយទទួលស្គាល់ព្រះយេស៊ូវ ជាយញ្ញបូជាលោះបាប និង ជាសម្តេចសង្ឃជាន់ខ្ពស់។ ចូរអានព្រះគម្ពីរដានីយ៉ែល ជំពូក ៨:១៣-១៤។ តើទេវតានៃព្រះបានប្រកាសប្រាប់អំពីពេលវេលាដែលមាន រហូតដល់រោងឧបោសថត្រូវបានលាងសម្អាត និងស្តារឡើងវិញ អស់រយៈពេលយូរប៉ុនណាដែរ?

២) ប្រសិនបើយើងប្រើគោលការណ៍នៃព្រះគម្ពីរ គឺថា ១ថ្ងៃនៅក្នុងបទទំនាយ ស្មើនឹង១ឆ្នាំ តើនៅក្នុងបទទំនាយនេះមានរយៈពេលប៉ុន្មានឆ្នាំ?

៣) យោងទៅតាមភាសាដើមនៃព្រះគម្ពីរដានីយ៉ែល ជំពូក ៨:១២ បានចែងអំពី ២៣០០នៃល្ងាចព្រឹក (ថ្ងៃ)។ ហោរាដានីយ៉ែលបានយល់ច្រលំជាខ្លាំង ទាក់ទងទៅនឹងបទទំនាយដែលមានរយៈពេលយូរ នៃ២៣០០ឆ្នាំ។ គាត់មិនបានទទួលការបើកសំដែង អំពីបទទំនាយនេះនឹងចាប់ផ្តើមនៅពេលណាឡើយ។ ចូរអានព្រះគម្ពីរដានីយ៉ែល ជំពូក៩:២៣ ហើយនិងឃ្លាដំបូងនៃខ ២៤។ យោងទៅតាមភាសាដើមបានចែងថា ៧០សប្តាហ៍តំណាងអោយ ៤៩០ឆ្នាំ ក៏និងចាប់ផ្តើមនៅក្នុងឆ្នាំ ៤៥៧B.C ត្រូវបានកាត់ចេញមកពីអ្វីមួយ។ វាធ្វើអោយយើងយល់អំពីកាលបរិច្ឆេទដែលចាប់ផ្តើមឡើង គឺដូចគ្នាសំរាប់វេលាទាំងពីរ ដោយសារតែការនេះគឺជាការឆ្លើយតបទៅនឹងសំនួររបស់ហោរាដានីយ៉ែលអំពី ២៣០០ថ្ងៃ (២៣០០ឆ្នាំ)។ ចូរមើលដ្យាក្រាមនៅក្នុងមេរៀនទី ១៧។ តើ ២៣០០ឆ្នាំនឹងត្រូវបញ្ចប់នៅក្នុងឆ្នាំណា?



៤) នៅក្នុងឆ្នាំ ១៨០០ មនុស្សជាច្រើនដែលនៅទូទាំងពិភពលោក ជាពិសេសនៅក្នុងសហរដ្ឋ បានសិក្សាទៅលើបទទំនាយនៅក្នុងព្រះគម្ពីរ។ ពួកគេបានជឿថាព្រះយេស៊ូវ នឹងយាងមកជាឆាប់ៗពួកអ្នកដែលបានសិក្សាទៅលើព្រះគម្ពីរដានីយ៉ែលបានរកឃើញនូវបទទំនាយនៃពេលវេលានេះ ធ្វើអោយពួកគេមានចិត្តត្រេកអរជាខ្លាំង ពីព្រោះពួកគេគិតថាព្រះយេស៊ូវនឹងយាងមកវិញ នៅខែតុលា ថ្ងៃទី ២២ ក្នុងឆ្នាំ ១៨៤៤ ដើម្បីនឹងសំអាតអំពើបាបចេញពីផែនដី។ ពួកគេមានការខកចិត្តជាខ្លាំង នៅពេលដែលព្រះទ្រង់មិនបានយាងមកតាមអ្វីដែលពួកគេបានគិត។ ចូរអានព្រះគម្ពីរវិវរណៈ ជំពូក ១០៖៨-១០។ តើមនុស្សលោកទទួលបានបទពិសោធន៍យ៉ាងដូចម្តេច នៅពេលដែលមានកំហុសឆ្គងនៅក្នុងការសិក្សាទៅលើបទទំនាយដ៏តូចក្នុងសៀវភៅដានីយ៉ែលដូចជាពួកគេទាំងនេះ?

៥) មនុស្សមួយចំនួនដែលបានខកចិត្ត ពួកគេបានបោះបង់ជំនឿរបស់ពួកគេទៅលើព្រះយេស៊ូវ នឹងការយាងមកវិញរបស់ទ្រង់។ មនុស្សមួយចំនួនទៀតបានសិក្សាបទទំនាយទាំងនោះឡើងវិញយ៉ាងយកចិត្តទុកដាក់ ហើយក៏បានរកឃើញនូវចំនុចដែលជាកំហុសឆ្គងរបស់ពួកគេ។ ពួកគេបានសិក្សាស្រាវជ្រាវ ហើយឃើញថាបទទំនាយទាំងនោះសំដៅទៅលើរោងឧបោសថដែលនៅឯស្ថានសួគ៌ មិនដូចជារោងឧបោសថនៅផែនដីនោះទេ។ ពួកគេបានជឿថា ភាពផ្អែម និងភាពល្វីងជូរចត់នៃការសិក្សាទៅលើបទទំនាយដ៏តូចក្នុងសៀវភៅដានីយ៉ែលដែលបានចែងទុកនៅក្នុងព្រះគម្ពីរវិវរណៈ ជំពូក១០ សំដៅទៅលើពួកគេនោះហើយ។ ចូរអានព្រះគម្ពីរវិវរណៈ ជំពូក ១០៖១១ តើពួកគេបានសិក្សាអំពីកិច្ចការអ្វីដែលពួកគេត្រូវតែធ្វើ មុនពេលព្រះយេស៊ូវយាងមកវិញ? (ចូលមើលព្រះគម្ពីរ ម៉ាថាយ ជំពូក ២៤៖១៤)

៦) មនុស្សមួយក្រុមនេះបានហៅខ្លួនឯងថា "អាត់វេនទីស្ទ" ដែលមានន័យថា ការយាងមកវិញរបស់ព្រះយេស៊ូវ ។ ពួកគេបានសិក្សាព្រះគម្ពីរ ដើម្បីអោយយល់ច្បាស់អំពីអត្ថន័យនៃការត្រៀមខ្លួនជាស្រេចសំរាប់ការយាងមកជាលើកទី ២ របស់ព្រះយេស៊ូវ ។ ចូរអានព្រះគម្ពីរ ពេត្រុសទី២ ជំពូក ៣៖១០-១៤។ ដោយសារតែព្រះទ្រង់ នឹង សំអាត អំពើបាបចេញពីសកលលោកដោយសារភ្លើង តើព្រះទ្រង់ត្រូវតែធ្វើកិច្ចការអ្វីនៅក្នុងយើងជាមុនសិន មុនពេលដែលព្រះយេស៊ូវទ្រង់យាងមកវិញ?

៧) អ្នកដែលមានជំនឿជាអាត់វេនទីស្ទទាំងឡាយ បានសិក្សាព្រះគម្ពីរដានីយ៉ែល ជំពូក ៨៖១៤ ដែលចាប់ផ្តើមឡើងនៅក្នុងឆ្នាំ១៨៤៤។ ព្រះទ្រង់នឹងបំពេញកិច្ចការថ្មីមួយនៃការជំនុំជំរះដែលទ្រង់នឹងសំអាតរោងឧបោសថនៅស្ថានសួគ៌ជាមុនសិន ដើម្បីរៀបចំការលាងសំអាតសកលលោកចេញពីអំពើបាប។ចូរអានព្រះគម្ពីរហេព្រើរ ជំពូក ៩៖២៣-២៤ និង៦ ២៧-២៨។ តើរោងឧបោសថនៅស្ថានសួគ៌ត្រូវបានលាងសំអាតយ៉ាងដូចម្តេច អោយចេញពីកំណត់ត្រានៃអំពើបាបរបស់យើង?

៨) ចូរអានព្រះគម្ពីរហេព្រើរ ជំពូក ១០៖១៩-២៣។ តើសេចក្តីសង្ឃឹមរបស់យើងនៅក្នុងប្រវត្តិសាស្រ្តនាពេលនេះគឺជាអ្វី នៅពេលដែលការជំនុំជំរះទៅលើគ្រីស្ទានដ៏ពិតកំពុងតែកើតឡើងនៅក្នុងរោងឧបោសថនៅស្ថានសួគ៌?

៩) ចូរពិចារណាយ៉ាងស្ងៀមស្ងាត់អំពីអ្វីដែលអ្នកបានរៀន។ ចូរទូលសូមដល់ព្រះ ដើម្បីអោយទ្រង់បំពេញនូវចន្លោះដែលខ្វះខាតនៅក្នុងចិត្ត និងជីវិតរបស់លោកអ្នកប្រសិនបើមាន ដើម្បីត្រៀមលក្ខណៈរួចជាស្រេចសំរាប់ការយាងមករបស់ព្រះយេស៊ូវ។

## ចែកចាយ និងអធិស្ឋាន

- □ នៅថ្ងៃនេះ តើលោកអ្នកបានរៀនអ្វីខ្លះដែលលោកអ្នកអាចនឹងយកទៅអនុវត្តនៅសប្តាហ៍នេះ ដោយពឹងលើអំណាចរបស់ព្រះជាម្ចាស់?
- □ ចូរពិភាក្សាអំពីសេចក្តីត្រូវការក្នុងគ្រួសារ និងសហគមន៍ព្រមទាំងការប្តេជ្ញាចិត្តរបស់លោកអ្នក ហើយសំរេចចិត្តថា តើមានអ្វីខ្លះដែលលោកអ្នកអាចជួយបាន?
- □ សូមអធិស្ឋានឲ្យគ្នាទៅវិញទៅមក សំរាប់គ្រួសារនិងសហគមន៍របស់លោកអ្នកនៅពេលឥឡូវនេះ។

## កិច្ចការពិសេស ឬកិច្ចអនុវត្តន៍

- □ ទន្ទេញខព្រះគម្ពីរទីតុស ជំពូក២៖១៤។
- □ ចែកចាយជាមួយអ្នកដទៃយ៉ាងហោចណាស់អោយបានម្នាក់ អំពីការជិតយាងមករបស់ព្រះយេស៊ូវ និងកិច្ចការដែលលោកអ្នកត្រូវធ្វើ ដើម្បីត្រៀមខ្លួនជាស្រេចក្នុងការទទួលទ្រង់។

(អត្ថបទផ្សេងៗទៀតដែលទាក់ទងទៅនឹងការយាងមករបស់ព្រះយេស៊ូវសំរាប់ការសិក្សាបន្ថែមទៀត មាននៅក្នុងព្រះគម្ពីរលេវីវិន័យ ជំពូក ៦)

# យល់ដឹងអំពីការប្រយុទ្ធ

## ពួកសាវ័កនាសម័យចុងក្រោយ មេរៀន ១៨



### សរសើរតម្កើងព្រះ និងអធិស្ឋាន

- តាំងពីយើងបានជួបគ្នាលើកមុនរហូតមកទល់ពេលនេះ តើមានរឿងអ្វីខ្លះដែលអ្នកចង់សរសើរតម្កើងព្រះ?
- តើមួយរយៈថ្មីនេះអ្នកមានក្តីបារម្ភអ្វីខ្លះ?
- សូមអធិស្ឋានសំរាប់សេចក្តីត្រូវការឲ្យគ្នាទៅវិញទៅមក។ ចូរទូលសូមព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណបរិសុទ្ធគង់ជាមួយក្នុងការជួបប្រជុំគ្នានេះ។

### ការរំឭកឡើងវិញ

- ចូរសូត្រខចងចាំកាលពីលើកមុនឡើងវិញជាមួយដៃគូម្នាក់ ឬពីរនាក់ផ្សេងទៀត។
- តើលោកអ្នកបានរៀនអ្វីខ្លះកាលពីលើកមុន?
- តើមានការប្រែប្រួលអ្វីខ្លះក្នុងជីវិតរបស់អ្នក ដោយព្រោះសេចក្តីពិតដែលអ្នកបានរៀនពីមេរៀនមុននោះ?
- តើលោកអ្នកបានចែករំលែកអ្វីដែលបានរៀនកន្លងមកទៅកាន់នរណាខ្លះ?

### ការសិក្សាព្រះបន្ទូល

១) ចូរអានព្រះគម្ពីរវិវរណៈជំពូក ១២៖១-២។ តើស្ត្រីនេះមានសភាពយ៉ាងដូចម្តេច?

២) ចូរអានព្រះគម្ពីរកូរិនថូសទី២ ជំពូក ១១៖២។ តើស្ត្រីនេះតំណាងអោយនរណា?

៣) ចូរអានព្រះគម្ពីរវិវរណៈ១២៖៣-៤ និងខ ៧-៩។ តើនាគដ៏ធំនោះគឺជានរណា?

៤) ចូរអានព្រះគម្ពីរអេសេគាល ជំពូក២៨៖១៤-១៩។ព្រះទ្រង់បានបង្កើតទេវតាដ៏ល្អឥតខ្ចោះមួយរូប តែមានព្រឹត្តិការណ៍អ្វីកើតឡើងដល់ទេវតានោះ?

៥) ចូរអានព្រះគម្ពីរវិវរណៈជំពូក ១៖២០។ តើបុគ្គលសំខាន់ណាខ្លះដែលសាតាំងបានយកចេញពីស្ថានសួគ៌?

៦) ចូរអានព្រះគម្ពីរវិវរណៈជំពូក ១២៖១០-១១។ តើវាមានអត្ថន័យយ៉ាងដូចម្តេច ដែលថាតាមរយៈឈាមនៃកូនចៀម និង ពាក្យសំដីនៃទីបន្ទាល់របស់ពួកគេ អាចយកឈ្នះលើសាតាំងបាន?

៧) ចូរអានព្រះគម្ពីរវិវរណៈជំពូក១២៖៥-៦ និងខ ១៣-១៦។ តើនាគបានធ្វើទុក្ខដល់ស្ត្រី អស់រយៈពេលយូរប៉ុនណា?
(ចំណាំ៖ មុននេះ យើងបានរៀនអំពីបទទំនាយក្នុងព្រះគម្ពីរដែលចែងថា ១ថ្ងៃស្មើនឹង១ឆ្នាំ។ សិស្សានុ - សិស្សនៃព្រះគម្ពីរជាច្រើនបានជឿថា ១២៦០ថ្ងៃនៅក្នុងអត្ថបទនេះ តំណាងអោយ ១២៦០ឆ្នាំដែលព្រះ

វិហារកាតូលិកនៃទីក្រុងរ៉ូមបានបៀតបៀនដល់ព្រះវិហារដ៏ពិតនៃព្រះ ចាប់តាំងពីឆ្នាំ ៥៣៨A.D រហូតដល់ឆ្នាំ ១៧៩៨A.D។ គ្រីស្ទានជាច្រើនលាននាក់បានត្រូវគេសំលាប់ និងគ្រីស្ទានជាច្រើននាក់ទៀតបានភៀសខ្លួនទៅតាមច្រកភ្នំ និងតាមទីរហោស្ថាននានា ជាទីកន្លែងដែលពួកគេអាចធ្វើតាមបទព្រះគម្ពីរដ៏ពិត ជាជាងការធ្វើតាមប្រពៃណី និង ច្បាប់នៃមនុស្ស។ នេះហើយគឺជាអ្វីដែលផែនដីបានជួយដល់ស្ត្រី ដែលជាព្រះវិហារដ៏ពិតរបស់ព្រះ)។

៨) ចូរអានព្រះគម្ពីរវិវរណៈជំពូក១២ៈ១៧។ តើគុណសម្បត្តិអ្វីខ្លះ មាននៅក្នុងរាស្ត្រសំរាំង ដែលធ្វើអោយសាតាំងស្អប់ នៅចុងបំផុតនៃការប្រយុទ្ធដ៏យូរនេះ?

៩) ចូរអានព្រះគម្ពីរវិវរណៈជំពូក១៩ៈ១០។ តើទីបន្ទាល់របស់ព្រះយេស៊ូវគឺជាអ្វី?
(ចំណាំៈសមាជិកព្រះវិហារសេវេនដេយអាត់វេនទីស្ទជាច្រើនជឿថាព្រះវិហាររបស់ពួកគេគឺជាព្រះវិហារសំរាំង មានន័យថា ពួកគេគឺជារាស្ត្រនៃសម័យចុងក្រោយដែលព្រះទ្រង់កំពុងតែប្រើ ដើម្បីអោយជួយរៀបចំពិភពលោកសំរាប់ការយាងមករបស់ព្រះយេស៊ូវ។ ពួកគេកាន់ក្រឹត្យវិន័យទាំងឡាយរបស់ព្រះយ៉ាងខ្ជាប់ខ្ជួន រួមទាំងការថែរក្សាថ្ងៃសប្ប័ទផងដែរ។ ពួកគេក៏បានជឿផងដែរថាព្រះទ្រង់បានលើកអ្នកស្រី អែល្លិន ជី វ៉ៃត៍ អោយក្លាយជាហោរាមួយរូបនៅក្នុងឆ្នាំ ១៨០០ រហូតដល់ឆ្នាំ ១៩០០ ដើម្បីជួយរៀបចំមនុស្សសំរាប់ការយាងមករបស់ព្រះយេស៊ូវ។ អ្នកស្រីបានទទួលការបើកសំដែងជាច្រើនដង ដើម្បីជួយមនុស្សអោយយល់កាន់តែច្បាស់ឡើង អំពីសេចក្តីពិតនៃបទបន្ទូលរបស់ព្រះ។ អ្នកស្រីបានចងក្រងសៀវភៅជាច្រើន ហើយក៏ជាកវីបកប្រែច្រើនជាងគេបំផុតដែរ នៅក្នុងចំនោមស្ត្រីទាំងអស់ទូទាំងពិភពលោក។ សៀវភៅរបស់អ្នកស្រីមួយចំនួនដែលគេចូលចិត្តអានបំផុតគឺ សៀវភៅព្រះនៃសេចក្តីស្រលាញ់ ជំហានទៅកាន់ព្រះគ្រិស្ត និងមហាវិវាទ។

១០) ចូរអានព្រះគម្ពីរអេភេសូរ ជំពូក៦ៈ១០-១៨។ តើគ្រឿងសឹកអ្វីខ្លះដែលព្រះទ្រង់បានប្រទានអោយយើង ដើម្បីយកឈ្នះលើសាតាំង និងពួកពលបរិវាររបស់វានាសម័យចុងក្រោយនេះ?

១១) ចូរពិចារណាយ៉ាងស្ងៀមស្ងាត់អំពីអ្វីដែលអ្នកបានរៀន។ ចូរទូលសូមដល់ព្រះ ដើម្បីអោយទ្រង់បំពេញនូវចន្លោះដែលខ្វះខាតនៅក្នុងចិត្ត និងជីវិតរបស់លោកអ្នកប្រសិនបើមាន ដើម្បីត្រៀមលក្ខណៈរួចជាស្រេចសំរាប់ការយាងមករបស់ព្រះយេស៊ូវ។

## ចែកចាយ និងអធិស្ឋាន

- □ នៅថ្ងៃនេះ តើលោកអ្នកបានរៀនអ្វីខ្លះដែលលោកអ្នកអាចនឹងយកទៅអនុវត្តនៅសប្តាហ៍នេះ ដោយពឹងលើអំណាចរបស់ព្រះជាម្ចាស់?
- □ ចូរពិភាក្សាអំពីសេចក្តីត្រូវការក្នុងគ្រួសារ និងសហគមន៍ព្រមទាំងការប្តេជ្ញាចិត្តរបស់លោកអ្នក ហើយសំរេចចិត្តថា តើមានអ្វីខ្លះដែលលោកអ្នកអាចជួយបាន?
- □ សូមអធិស្ឋានឲ្យគ្នាទៅវិញទៅមក សំរាប់គ្រួសារនិងសហគមន៍របស់លោកអ្នកនៅពេលឥឡូវនេះ។

## កិច្ចការពិសេស ឬកិច្ចអនុវត្តន៍

- □ ទន្ទេញខព្រះគម្ពីរវិវរណៈជំពូក១២ៈ១១។
- □ ចូរចែកចាយប្រាប់ទៅអ្នកដទៃឲ្យបានយ៉ាងតិចណាស់ម្នាក់អំពីការយាងមកវិញឆាប់ៗរបស់ព្រះយេស៊ូវ និង របៀបត្រៀមខ្លួនទទួលព្រះអង្គ។

(អត្ថបទផ្សេងៗទៀតដែលទាក់ទងទៅនឹងការយាងមករបស់ព្រះយេស៊ូវសំរាប់ការសិក្សាបន្ថែមទៀត មាននៅក្នុងព្រះគម្ពីរអេសាយ ជំពូក១៤ៈ១២-១៦, ម៉ាថាយ ជំពូក១៩ៈ១៧-២១, យ៉ូអែល ជំពូក ២ៈ២៨-២៩ និង ថែស្សាឡូនីចទី១ ជំពូក៥ៈ១៩-២០)

# ចូរស្រលាញ់ព្រះឱ្យច្រើនជាងស្រលាញ់មនុស្ស ជាងការសប្បាយ និងជាងជីវិតខ្លួនឯង

## ពួកសាវ័កនាសម័យចុងក្រោយ មេរៀន ១៩



### សរសើរតម្កើងព្រះ និងអធិស្ឋាន

- តាំងពីយើងបានជួបគ្នាលើកមុនរហូតមកទល់ពេលនេះ តើមានរឿងអ្វីខ្លះដែលអ្នកចង់សរសើរតម្កើងព្រះ?
- តើមួយរយៈថ្មីនេះអ្នកមានក្តីបារម្ភអ្វីខ្លះ?
- សូមអធិស្ឋានសំរាប់សេចក្តីត្រូវការឲ្យគ្នាទៅវិញទៅមក។ ចូរទូលសូមព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណបរិសុទ្ធគង់ជាមួយក្នុងការជួបប្រជុំគ្នានេះ។

### ការរំឭកឡើងវិញ

- ចូរសូត្រខចងចាំកាលពីលើកមុនឡើងវិញជាមួយដៃគូម្នាក់ ឬពីរនាក់ផ្សេងទៀត។
- តើលោកអ្នកបានរៀនអ្វីខ្លះកាលពីលើកមុន?
- តើមានការប្រែប្រួលអ្វីខ្លះក្នុងជីវិតរបស់អ្នក ដោយព្រោះសេចក្តីពិតដែលអ្នកបានរៀនពីមេរៀនមុននោះ?
- តើលោកអ្នកបានចែករំលែកអ្វីដែលបានរៀនកន្លងមកទៅកាន់នរណាខ្លះ?

### ការសិក្សាព្រះបន្ទូល

១) សូមអានព្រះគម្ពីរវិវរណៈ ១៣:១,៥-៦។ ដែលយើងបានរៀនពីព្រះគម្ពីរដានីយ៉ែល តើមេរៀននេះរំលឹកអ្នកពីអ្នកណា ។
(ចំណាំ: សត្វសាហាវដែលចេញពីសមុទ្រនេះ គឺដូចជាស្នែងតូចដែល ជាអ្នកប្រមាថព្រះ ដែលវាយប្រហាររោងឧបោសថរបស់ព្រះ និងបានធ្វើទុក្ខបៀតបៀនដល់អ្នកដែលដើរតាមព្រះគ្រិស្តពិតប្រាកដក្នុងរយៈពេល ១២៦០ ថ្ងៃ (ឬឆ្នាំ) ដែលបានសរសេរនៅទីនេះរយៈពេល៤២ខែ រាប់ជាមួយខែ៣០ថ្ងៃ។ សត្វសមុទ្រគឺតំណាងឲ្យព្រះវិហារកាតូលិក)។

២) សូមអានព្រះគម្ពីរវិវរណៈ១៣:៣,៨។ តើការផ្សព្វផ្សាយនេះនឹងមានឥទ្ធិពលលើព្រះវិហារកាតូលិកដោយរបៀបណា?
(ចំណាំ: នៅក្នុងមេរៀនមុន ពួកយើងបានឃើញថាព្រះវិហារកាតូលិកមានអំនាច១២៦០ឆ្នាំ ពីឆ្នាំ៥៣៨ ដល់ ១៧៩៨។ ណេប៉ូលេអុងបានចាត់សម្តេចសង្ឃជាឈ្លើយក្នុងឆ្នាំ១៧៩៨ ហើយព្រះវិហារកាតូលិកបានធ្លាក់អំនាច។ នេះគឺជាដំបៅដែលនៅខ៣និយាយថាវាបានជាសះស្បើយហើយ។សព្វថ្ងៃនេះមានកាតូលិកជាង១កោដនាក់ដែលមានតែសម្តេចសង្ឃតែមួយអង្គគត់ដែលមានឥទ្ធិពលលើពិភពទាំងមូលនោះ)។

៣) សូមអានព្រះគម្ពីរវិវរណៈ១៣:១១-១៣។ សត្វសាហាវទី២នេះបានចេញមកពីក្នុងដី ជំនួសការចេញពីសមុទ្រដូចសត្វទី១ សមុទ្រតំណាងឲ្យតំបន់ដែលមានមនុស្សជាច្រើន (វិវរណៈ១៧:១៥)។ ផែនដីតំណាងឲ្យកន្លែងដែលមានមនុស្សរស់នៅតិចតួច។ នៅក្នុងផ្នែកមួយនៃពិភពលោកដែលមិនសូវមានមនុស្សរស់នៅច្រើន ហាក់ដូចជាកូនចៀម (គឺដូចជាព្រះគ្រិស្ត) ប៉ុន្តែបាននិយាយថាដូចជាសត្វនាគ (គឺសាតាំង) ដែលមានឥទ្ធិពលលើពិភពលោក  តើជាតិសាសន៍អ្វីដែលបានលេចចេញមកក្នុងឆ្នាំ១៧៩៨?
(ចំណាំ: សហរដ្ឋអាមេរិកគឺជាប្រទេសមួយដែលកើតឡើងក្នុងទសវត្សរ៍ទី១៧ ពីកន្លែងទី១ដែលមានមនុស្សពីរបីនាក់ដែលមានគោលការណ៍គ្រីស្ទាននៅក្នុងរដ្ឋាភិបាលនោះ ហើយឥឡូវនេះមានអំនាចជាងគេលើពិភពលោក។ អំនាចរបស់វាទាំងល្អនិងអាក្រក់ត្រូវបានគ្របដណ្តប់លើពិភពលោកតាមរយៈអំនាចយោធាសេដ្ឋកិច្ចដ៏ធំសំបើម និងវិស័យឧស្សាហកម្មដែលបានបកប្រែទៅជារាប់រយភាសានៅជុំវិញពិភពលោក)។

៤) អានព្រះគម្ពីរវិវរណៈ១៣:១៣-១៥។ សត្វសាហាវដែលនៅលើដីនឹងធ្វើការស្រដៀងនឹងសត្វសាហាវដែលចេញពីសមុទ្រដែលហើយវានឹងធ្វើរូបវាឲ្យដូចជារូបសត្វនោះ។ ចាប់តាំងពីព្រះវិហារកាតូលិកបានជំនួសច្បាប់របស់ព្រះជាមួយនឹងទំនៀមទំលាប់ខ្លួនគេផ្ទាល់ហើយបង្ខំអ្នកដែលដើរតាមព្រះគ្រិស្តពិតប្រាកដអោយធ្វើតាមបង្គាប់ឬក៏ត្រូវស្លាប់ តើអាមេរិកនឹងធ្វើអ្វីនៅថ្ងៃអនាគត?

៥) យោងទៅតាមព្រះគម្ពីរវិវរណៈ១៣:១៥-១៧ សត្វសាហាវលើដីនឹងបង្ខំមនុស្សទាំងអស់ឲ្យធ្វើតាមការថ្វាយបង្គំរបស់ពួកវា ដែលពួកគេមិនអាចលក់ ឬទិញ ឬមិនអាចរស់នៅបានប្រសិនបើពួកគេមិនគោរពតាមច្បាប់របស់ពួកវា។ អានព្រះគម្ពីរលូកា១៤:២៦-២៧,៣៣។តើព្រះយេស៊ូវតំរូវឲ្យអ្នកដើរតាមទ្រង់ស្រលាញ់ទ្រង់លើសជាងរបស់អ្វី?

៦) អានព្រះគម្ពីរវិវរណៈ១៣:១៧-១៨។ តើលេខ៦៦៦តំណាងឲ្យអ្វី? (ចំណាំ: សិស្សប្រវត្តិវិទ្យាជាច្រើនបានចំណាំថា ឈ្មោះរបស់សម្តេចសង្ឃគឺ "វីការៀស ហ្វីលី ដេ"(Vicarius Filii Dei) ។ ឈ្មោះនេះនៅក្នុងភាសា ឡាតាំងដែលបែងចែកជាលេខនៅក្នុងតួអក្សរនីមួយៗ។ ការបូកបញ្ចូលអក្សរទាំងនេះស្មើនឹង៦៦៦ ដែលចង្អុលបង្ហាញពីព្រះវិហារកាតូលិក។

| | | |
|---|---|---|
| V=5 | F=0 | D=500 |
| I=1 | I=1 | E=0 |
| C=100 | L=50 | I=1 |
| A=0 | I=1 | 501 |
| R=0 | I=1 | |
| I=1 | 53 | |
| U=5 | | |
| S=0 | | |
| 112 | | |

112+53+501=666

៧) យោងទៅតាមព្រះគម្ពីរវិវរណៈ១៣:១២,១៥ បញ្ហាដ៏ធំចុងក្រោយនៅក្នុងពិភពលោកយើងនេះគឺអំពីការថ្វាយបង្គំ។ អាននិក្ខមនំ២០:៨-១១។ តើព្រះឲ្យប្រជាជនរបស់ទ្រង់ថ្វាយបង្គំព្រះអង្គយ៉ាងដូចម្តេច?

៨) អានព្រះគម្ពីរវិវរណៈ៧:១-៤។ ហេតុអ្វីបានជាព្រះឲ្យទេវតាទប់ខ្យល់មិនឲ្យបក់មកលើផែនដី។

៩) អានគម្ពីរវិវរណៈ១៤:១ និងអេសេគាល២០:១២,២០។ ប្រសិនបើសញ្ញាសំគាល់គឺជាទំរង់ក្លែងក្លាយនៃការថ្វាយបង្គំរបស់គ្រិស្តបរិស័ទ តើត្រាអ្វីរបស់ព្រះជាម្ចាស់ដែលនៅលើថ្ងាសរបស់យើង។

១០) វាអាចជារឿងដែលគួរឲ្យភ័យខ្លាចដែលគិតពីការបៀតបៀនដែលនឹងមកដល់។អានថែស្សាឡូនីច៥:២៣-២៤។ តើព្រះទ្រង់សន្យាថានឹងធ្វើអ្វីសំរាប់យើង?

១១)យកពេលវេលាគិតអំពីអ្វីដែលអ្នកបានរៀន។ សូមព្រះឲ្យបង្ហាញប្រសិនបើមានអ្វីដែលត្រូវផ្លាស់ប្តូរក្នុងចិត្តគំនិត ឬក៏ក្នុងជីវិតអ្នកដើម្បីឲ្យបានត្រៀមខ្លួនជាស្រេចសំរាប់ការយាងមករបស់ព្រះយេស៊ូវ។

## ចែកចាយ និងអធិស្ឋាន

- នៅថ្ងៃនេះ តើលោកអ្នកបានរៀនអ្វីខ្លះដែលលោកអ្នកអាចនឹងយកទៅអនុវត្តនៅសប្តាហ៍នេះ ដោយពឹងលើអំណាចរបស់ព្រះជាម្ចាស់?
- ចូរពិភាក្សាអំពីសេចក្តីត្រូវការក្នុងគ្រួសារ និងសហគមន៍ព្រមទាំងការប្តេជ្ញាចិត្តរបស់លោកអ្នក ហើយសំរេចចិត្តថា តើមានអ្វីខ្លះដែលលោកអ្នកអាចជួយបាន?
- សូមអធិស្ឋានឲ្យគ្នាទៅវិញទៅមក សំរាប់គ្រួសារនិងសហគមន៍របស់លោកអ្នកនៅពេលឥឡូវនេះ។

## កិច្ចការពិសេស ឬកិច្ចអនុវត្តន៍

- ទន្ទេញគម្ពីរ ម៉ាថាយ១០:៣៩។
- ចូរចែកចាយប្រាប់ទៅអ្នកដទៃឲ្យបានយ៉ាងតិចណាស់ម្នាក់អំពីការយាងមកវិញឆាប់ៗរបស់ព្រះយេស៊ូវ និង របៀបត្រៀមខ្លួនទទួលព្រះអង្គ។

អត្ថបទមួយទៀតអំពីការយាងមករបស់ព្រះយេស៊ូវសំរាប់ការសិក្សាថ្ងៃក្រោយគឺ ព្រះគម្ពីរដានីយ៉ែល ជំពូក ៧-៨ និងថែស្សាឡូនីចទី១ ២:១-១២។

# ការប្រកាសសាររបស់ទេវតាទាំងបី

## ពួកសាវ័កនាសម័យចុងក្រោយ មេរៀន ទី២០



## សរសើរតម្កើងព្រះ និងអធិស្ឋាន

- តាំងពីយើងបានជួបគ្នាលើកមុនរហូតមកទល់ពេលនេះ តើមានរឿងអ្វីខ្លះដែលអ្នកចង់សរសើរតម្កើងព្រះ?
- តើមួយរយៈថ្មីនេះអ្នកមានក្តីបារម្ភអ្វីខ្លះ?
- សូមអធិស្ឋានសំរាប់សេចក្តីត្រូវការឲ្យគ្នាទៅវិញទៅមក។ ចូរទូលសូមព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណបរិសុទ្ធគង់ជាមួយក្នុងការជួបប្រជុំគ្នានេះ។

## ការរំឭកឡើងវិញ

- ចូរសូត្រខចងចាំកាលពីលើកមុនឡើងវិញជាមួយដៃគូម្នាក់ ឬពីរនាក់ផ្សេងទៀត។
- តើលោកអ្នកបានរៀនអ្វីខ្លះកាលពីលើកមុន?
- តើមានការប្រែប្រួលអ្វីខ្លះក្នុងជីវិតរបស់អ្នក ដោយព្រោះសេចក្តីពិតដែលអ្នកបានរៀនពីមេរៀនមុននោះ?
- តើលោកអ្នកបានចែករំលែកអ្វីដែលបានរៀនកន្លងមកទៅកាន់នរណាខ្លះ?

## ការសិក្សាព្រះបន្ទូល

១) អានវិវរណៈ ១៤:៦។ តើទេវតាអង្គនេះថ្លែងពីអ្វី?

២) អាន ម៉ាថាយ ២៨:១៨-២០។ តើព្រះយេស៊ូវប្រាប់អ្នកណាឲ្យទៅបង្កើតសិស្សពាសពេញពិភពលោក?

៣) ទេវតាទាំងបីនៅក្នុងវិវរណៈ១៤តំណាងឲ្យសាររបស់ព្រះ សំរាប់អ្នកនិងខ្ញុំ។ អានវិវរណៈ១៤:៧។ តើយើងត្រូវតែប្រាប់ដល់មនុស្សអំពីអ្វី? ពំណានាពីអ្វីដែលអ្នកគិតពីអត្ថន័យនៃ "ការកោតខ្លាចព្រះ" "ថ្វាយសិរីល្អដល់ទ្រង់" និង "ការថ្វាយបង្គំ" ព្រះអាទិករ.
(ចំណាំ យើងបានរៀនជាច្រើនអំពីការជំនុំជំរះ ហើយត្រូវបានបញ្ជាក់យ៉ាងច្បាស់ថាយើងត្រូវតែកោតខ្លាចភាពបរិសុទ្ធរបស់ព្រះ ហើយបែរចេញពីអំពើបាប។ ប៉ុន្តែ យើងមិនដែលត្រូវខ្លាចព្រះទ័យដែលពោរពេញដោយក្តីស្រលាញ់របស់ទ្រង់ទេ ផ្ទុយទៅវិញយើងត្រូវតែថ្វាយសិរីល្អដល់ព្រះយេស៊ូវដែលទ្រង់បានសុគតជំនួសយើង ហើយទុកចិត្តព្រះអាទិករដែលទ្រង់បានប្រទានគ្រប់យ៉ាងដល់យើង)។

៤) អានវិវរណៈ១៤:៨ និង១៧:៣-៦។ សំអាងលើអ្វីដែលយើងបានសិក្សាពីមុនអំពីក្រុមជំនុំពិតប្រាកដ និងក្រុមជំនុំក្លែងក្លាយ តើអ្នកណាជាបាប៊ីឡូន?

( ចំណាំ ការប្រកាសពីសាររបស់ទេវតាទីពីរថា បាប៊ីឡូនរលំហើយ យើងត្រូវតែបង្ហាញមនុស្សម្នាដោយ សេចក្តីស្រលាញ់មិនឲ្យជឿលើសាសនា ពិធីបុណ្យ ឬក៏សង្ឃណាឲ្យសោះ ប៉ុន្តែត្រូវ ជឿលើព្រះយេស៊ូវ មួយអង្គតែប៉ុណ្ណោះ)។

៥) អានវិវរណៈ១៤:៩-១២។ តើមនុស្សជំនាន់ចុងក្រោយរបស់ព្រះត្រូវជាស់តឿនពិភពលោកអំពីអ្វី?

៦) អានម៉ាឡាគី៤:១។ តើសារនេះជួយយើងឲ្យដឹងពីភ្លើងដែលឆេះអស់កល្បនៅស្ថាននរក ឆេះរហូត ទាល់តែរបស់សព្វសារពើត្រូវបានបំផ្លាញអស់ដោយរបៀបណា?

៧) អានវិវរណៈ១៤:១៤-២០។ ក្រុមមនុស្សពីរក្រុមដែលទំជាស្រេចនៅពេលដែលព្រះយេស៊ូវយាងមកវិញ តើទាំងពីរក្រុមនោះតំណាងឲ្យអ្វី?

៨) អានវិវរណៈ១៤:១-៥។ តើអ្វីដែលជានិមិត្តរូបដែលប្រាប់យើងអំពីក្រុមមនុស្សដែលត្រៀមខ្លួនជាស្រេច នឹងចូលទៅនគរស្ថានសួគ៌នៅពេលព្រះយេស៊ូវយាងត្រឡប់មកវិញ?
(ចំណាំ បទទំនាយប្រើប្រាស់និមិត្តសញ្ញា។ លេខ១៤៤,000ជាលេខល្អឥតខ្ចោះដែលជានិមិត្តរូប តំណាងឲ្យក្រុមមនុស្សចុងក្រោយដែលមានចរិតលក្ខណៈរបស់ព្រះនៅក្នុងចិត្តរបស់ពួកគេ ជាក្រុម មនុស្សដែលថ្វាយខ្លួនទាំងស្រុងចំពោះព្រះ ហើយនឹងយកឈ្នះលើអំពើបាបតាមរយៈអំនាចរបស់ ព្រះយេស៊ូវ)។

៩) អានវិវរណៈ១៤:១២។ តើអ្វីជាសេចក្តីសង្ឃឹមនៅពេលចុងក្រោយរបស់យើង?

១០) យកពេលគិតអំពីអ្វីដែលយើងបានរៀន។ សូមព្រះទ្រង់បង្ហាញអ្នកប្រសិនបើមានអ្វីដែលត្រូវផ្លាស់ប្តូរ ក្នុងចិត្តគំនិត ឬក៏ក្នុងជីវិតរបស់អ្នកដើម្បីឲ្យបានត្រៀមខ្លួនជាស្រេចសំរាប់ការយាងមករបស់ ព្រះយេស៊ូវ។

## ចែកចាយ និងអធិស្ឋាន

- □ នៅថ្ងៃនេះ តើលោកអ្នកបានរៀនអ្វីខ្លះដែលលោកអ្នកអាចនឹងយកទៅអនុវត្តនៅសប្តាហ៍នេះ ដោយពឹងលើអំណាចរបស់ព្រះជាម្ចាស់?
- □ ចូរពិភាក្សាអំពីសេចក្តីត្រូវការក្នុងគ្រួសារ និងសហគមន៍ព្រមទាំងការប្តេជ្ញាចិត្តរបស់លោកអ្នក ហើយសំរេចចិត្តថា តើមានអ្វីខ្លះដែលលោកអ្នកអាចជួយបាន?
- □ សូមអធិស្ឋានឲ្យគ្នាទៅវិញទៅមក សំរាប់គ្រួសារនិងសហគមន៍របស់លោកអ្នកនៅពេលឥឡូវនេះ។

## កិច្ចការពិសេស ឬកិច្ចអនុវត្តន៍

- □ ទន្ទេញគម្ពីរ វិវរណៈ១៤:១២។
- □ ចូរចែកចាយប្រាប់ទៅអ្នកដទៃឲ្យបានយ៉ាងតិចណាស់ម្នាក់អំពីការយាងមកវិញឆាប់ៗរបស់ព្រះ យេស៊ូវ និង របៀបត្រៀមខ្លួនទទួលព្រះអង្គ។

(អត្ថបទមួយទៀតអំពីការយាងមករបស់ព្រះយេស៊ូវសំរាប់ការសិក្សាថ្ងៃក្រោយគឺ ព្រះគម្ពីរវិវរណៈ ៧:១-១៧ វិវរណៈ១៨:១-៨)។

# ការទទួលភ្លៀងចុងរដូវ

## ពួកសាវ័កនាសម័យចុងក្រោយ មេរៀន ទី២១



## សរសើរតម្កើងព្រះ និងអធិស្ឋាន

- តាំងពីយើងបានជួបគ្នាលើកមុនរហូតមកទល់ពេលនេះ តើមានរឿងអ្វីខ្លះដែលអ្នកចង់សរសើរតម្កើងព្រះ?
- តើមួយរយៈថ្មីនេះអ្នកមានក្តីបារម្ភអ្វីខ្លះ?
- សូមអធិស្ឋានសំរាប់សេចក្តីត្រូវការឲ្យគ្នាទៅវិញទៅមក។ ចូរទូលសូមព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណបរិសុទ្ធគង់ជាមួយក្នុងការជួបប្រជុំគ្នានេះ។

## ការរំឮកឡើងវិញ

- ចូរសូត្រខចងចាំកាលពីលើកមុនឡើងវិញជាមួយដៃគូម្នាក់ ឬពីរនាក់ផ្សេងទៀត។
- តើលោកអ្នកបានរៀនអ្វីខ្លះកាលពីលើកមុន?
- តើមានការប្រែប្រួលអ្វីខ្លះក្នុងជីវិតរបស់អ្នក ដោយព្រោះសេចក្តីពិតដែលអ្នកបានរៀនពីមេរៀនមុននោះ?
- តើលោកអ្នកបានចែករំលែកអ្វីដែលបានរៀនកន្លងមកទៅកាន់នរណាខ្លះ?

## ការសិក្សាព្រះបន្ទូល

១) អានវិវរណៈ៣:១៤-១៧។ តើព្រះវិហារនេះមានកំហុសអ្វី?
(ចំណាំ ក្រុមជំនុំឡៅឌីសេមានន័យថា "មនុស្សដែលត្រូវគេជំនុំជំរះ"។ ជាពិសេស វាឆ្លុះបញ្ចាំងពីក្រុមជំនុំចុងក្រោយរបស់ព្រះ ដែលបានសម្របសម្រួលជំនឿរបស់ពួកគេ ប៉ុន្តែបានបាត់បង់ការខិតខំខ្នះខ្នែងយ៉ាងខ្លាំងរបស់ពួកគេទៅហើយ)។

២) អានវិវរណៈ ៣:១៨-២១។ តើព្រះយេស៊ូវប្រាប់ក្រុមជំនុំឡៅឌីសេថាត្រូវតែធ្វើអ្វីខ្លះ?

៣) ដើម្បីឲ្យយល់ពីព្រះរាជសាររបស់ព្រះយេស៊ូវ យើងត្រូវប្រៀបធៀបសារនេះជាមួយនឹងសារផ្សេងទៀត។ សូមអានយ៉ូហាន ១៦:៧-៨, ១៣។ តើនរណាជួយឲ្យយើងមើលឃើញអំពើបាបរបស់យើង និងមើលឃើញសេចក្តីល្អដែលព្រះបានធ្វើសំរាប់យើង ដែលប្រៀបបាននឹងថ្នាំលាបភ្នែក?

៤) អានអេសាយ៦១:១០។ តើសំលៀកបំពាក់ព័ណសតំណាងឲ្យអ្វី?

៥) អានពេត្រុសទី១ ១:៦-៧។ តើមាសអ្វីដែលក្រុមជំនុំចុងក្រោយរបស់ព្រះត្រូវការជាចាំបាច់?

៦) ព្រះយេស៊ូវបានមានព្រះបន្ទូលថា យើងត្រូវតែទិញរបស់ទាំងនោះពីទ្រង់។ ក្នុងកាលដែលយើងទ័លក្រ ហើយនៅអាក្រាត តើយើងអាចឲ្យអ្វីដល់ទ្រង់ ដើម្បីឲ្យទិញរបស់ទាំងនោះសំរាប់យើង?

៧) អាន យ៉ូអែល២:២៣,២៨-២៩។ តើព្រះទ្រង់សន្យាអ្វីនៅពេលចុងក្រោយ?
(ចំណាំ ភ្លៀងនិងទឹកជានិមិត្តរូបតំណាងឲ្យព្រះវិញ្ញាណបរិសុទ្ធ។ នៅមជ្ឈិមបូព៌ាប្រទេស នៅសម័យព្រះយេស៊ូវភ្លៀងធ្លាក់នៅពេលចាប់ផ្តើមច្រូតកាត់ ហើយក៏ធ្លាក់ក្នុងរដូវដាំដុះ។ នៅពេលភ្លៀងចុងក្រោយច្រើនធ្លាក់មកចុងរដូវកាលដែលគ្រប់ធញ្ញជាតិទុំ។ នេះគឺជាអ្វីដែលយើងរង់ចាំនៅក្នុងពន្លឺនិងសេចក្តីសន្យាទាំងនេះនៅក្នុងព្រះគម្ពីរ។ ព្រះនឹងបញ្ជូនព្រះវិញ្ញាណបរិសុទ្ធជាចំនែកយ៉ាងធំក្នុងការបញ្ចប់កិច្ចការនៅក្នុងចិត្តមនុស្សនិងដល់ពិភពលោក។ យើងគប្បីអធិដ្ឋានរាល់ថ្ងៃដើម្បីឲ្យព្រះវិញ្ញាណបរិសុទ្ធនាំមកនូវសេចក្តីសុចរិត សេចក្តីស្រលាញ់ និងជំនឿរបស់ព្រះយេស៊ូវ)។

៨) អានអេសាយ៦០:១-៣ និង អេសាយ ៦១:១-៣។ តើមានអ្វីកើតឡើងនៅពេលដែលព្រះវិញ្ញាណបរិសុទ្ធចាក់បំពេញលើប្រជារាស្ត្ររបស់ទ្រង់?

៩) អានវិវរណៈ១៨:១-៥។ សិរីល្អរបស់ព្រះចាក់បំពេញលើផែនដី នៅពេលចុងបញ្ចប់ តើអ្វីដែលយើងត្រូវនិយាយទៅកាន់មនុស្សដែលនៅជុំវិញយើង?

១០) យកពេលគិតអំពីអ្វីដែលយើងបានរៀន។ សូមព្រះបង្ហាញយើង ប្រសិនបើមានអ្វីដែលត្រូវផ្លាស់ប្តូរក្នុងចិត្តគំនិត ឬក៏ក្នុងជីវិតដើម្បីឲ្យបានត្រៀមខ្លួនជាស្រេចសំរាប់ការយាងមករបស់ព្រះយេស៊ូវ។

## ចែកចាយ និងអធិស្ឋាន

- □ នៅថ្ងៃនេះ តើលោកអ្នកបានរៀនអ្វីខ្លះដែលលោកអ្នកអាចនឹងយកទៅអនុវត្តនៅសប្តាហ៍នេះដោយពឹងលើអំណាចរបស់ព្រះជាម្ចាស់?
- □ ចូរពិភាក្សាអំពីសេចក្តីត្រូវការក្នុងគ្រួសារ និងសហគមន៍ព្រមទាំងការប្តេជ្ញាចិត្តរបស់លោកអ្នក ហើយសំរេចចិត្តថា តើមានអ្វីខ្លះដែលលោកអ្នកអាចជួយបាន?
- □ សូមអធិស្ឋានឲ្យគ្នាទៅវិញទៅមក សំរាប់គ្រួសារនិងសហគមន៍របស់លោកអ្នកនៅពេលឥឡូវនេះ។

## កិច្ចការពិសេស ឬកិច្ចអនុវត្តន៍

- □ ទន្ទេញគម្ពីរ វិវរណៈ៣:២០-២១។
- □ សូមចែកចាយនូវអ្វីដែលអ្នកដឹងអំពីការយាងមកឆាប់ៗរបស់ព្រះយេស៊ូវ និងពីរបៀបត្រៀមខ្លួនឲ្យរួចជាស្រេចជាមួយមនុស្សយ៉ាងហោចណាស់អោយបានម្នាក់។

(អត្ថបទមួយទៀតអំពីការយាងមករបស់ព្រះយេស៊ូវសំរាប់ការសិក្សាថ្ងៃក្រោយគឺ ព្រះគម្ពីរយ៉ាកុប៥:៧ សាការី១០:១ យ៉ូហាន៧:៣៧-៣៩) ។